1461

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភិយ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសត្ថា ស្វរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនបណ្ឌិត្យ | សេចក្ដីជូនដំណឹង រឿងទស្សនាវដ្ដី ......... | ៧២១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | ព្រះរាជក្រឹត្យ ក្រមទសករិយា (តមក) ....... | ៧២៨ |
| លោក ម៉ុញ - តាគ្រី | ស័ព្ទបារាំងប្រែជាខ្មែរ (តមក) ............. | ៧៣១ |
| លោកសាង - សាភិត លេខានុការ | រឿងព្រៃគភូមា (តមក)..................... | ៧៣៦ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ - កន | រឿងសាមកុក (តមក) ....................... | ៧៤៤ |
| — ទេពពិទូរ ឈឹម - ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)... ... | ៧៥១ |
| អ្នកអង្គម្ចាស់ក្សត្រី ន. សុខាតារី | សាវតារវត្តអង្គារស (ត_ចប់) ................ | ៧៥៦ |
| លោកផែង - ដិរ | ប្រវត្តិរបស់អេសុប (តមក) ................. | ៧៦៣ |
| **ផ្នែកសាសនា** | | |
| អ្នកឧកញ៉ាទេពពិទូរឈឹមក្រសេម | ប្រវត្តិព្រះកែវមរកត (ត - ចប់) ............... | ៧៦៧ |
| សាមណេរ គក - គីឡេង | រឿងនាគបជាបារ (ត - ចប់) .................. | ៧៧៩ |
| លោក អ៊ុម - គយ សាស្ត្រាចារ្យ | ប្រវត្តិព្រាហ្មណ៍ចាស់ (ត - ចប់) ............... | ៧៨៦ |
| **កំណត់ទិនប្រវត្តិការណ៍** | | |
| ពុទ្ធសាសនបណ្ឌិត្យ | ពិធីផ្ទេរពុទ្ធសាសនបណ្ឌិត្យ ជូនមករាជរដ្ឋាភិបាលខ្មែរ ......................... | ៧៩២ |

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

# TABLE DES MATIÈRES

## Partie littéraire


| | | page |
|---|---|---|
| Institut Bouddhique | Annonce de la Revue Kambujà Suriyà 1950 | 721 |
| Luong Nibandhamantri Nhok-Thèm | Edit royal: Kramadasabhariyâ (suite) | 725 |
| M. Menh-Nakry ancien député | Recueil des mots traduits par la Commission Culturelle (suite) | 731 |
| M. Sang-Savath Secrétaire au Ministère des Finances | Contes birmans (suite) | 736 |
| Neak Oknha Vibularajaséna Nou-Kân | Histoire de SAMKOK (suite) | 744 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite) | 751 |
| Contesse Norodom Sukhanari, secrétaire de la Commission des Mœurs et Coutumes | Notice historique de Vat Attharasa (suite et fin) | 756 |
| M. Pheng Chhieu, professeur au Collège des Jeunes Filles | Biographie d'Esope (suite) | 763 |


## Partie religieuse:


| | | |
|---|---|---|
| Neak oknha Debabidura Chhim-Krasem | Historique du Bouddha d' Emeraude (suite) | 768 |
| Samanera Kok-Kileng | Histoire de Neang Patâcâra (poème) (suite et fin) | 779 |
| M. Oum Koy professeur à l'Ecole supérieure de Pali | Histoire d'un vieux brahman (suite et fin) | 786 |


## Notes et Chroniques


| | | |
|---|---|---|
| Institut Bouddhique | Cérémonies de transfert de l'Institut Bouddhique au Gouvernement Royal | 792 |

ÉCOLE FRANÇAISE D'EXTRÊME-ORIENT BIBLIOTHÈQUE

# សេចក្តីជូនដំណឹង
# អំពីពុទ្ធសាសនបណ្ឌិត្យ
## រឿងទស្សនាវដ្តី កម្ពុជសុរិយា

សូមជំរាបជូនដំណឹងដល់បងប្អូនរួមជាតិទាំងឡាយ !

ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៥០ នេះ អស់លោកអ្នកបានចុះឈ្មោះជាវ មានចំនួនច្រើនជាងឆ្នាំមុនៗ ។ ពុទ្ធសាសនបណ្ឌិត្យបានយល់ឃើញជាក់ស្តែងថា អស់លោក អ្នកស្រឡាញ់អក្សរសាស្ត្រ ទាំងឧបត្ថម្ភអក្សរសាស្ត្ររបស់ជាតិ ឲ្យលូតលាស់ចំរើនឡើងដោយពិតៗ ។ កិច្ចដែលបងប្អូនរួមជាតិស្ម័គ្រចុះឈ្មោះជាវច្រើនឡើងៗ នេះ ឈ្មោះថាឲ្យកម្លាំងដល់ពួកអ្នកនិពន្ធក្នុងក្រុមយើង ឲ្យខំតែងខំរៀបរៀងនូវរឿងរ៉ាវថ្មីៗ ដែលមានសារប្រយោជន៍ច្រើន ទាំងខំរៀបចំរបៀបពាក្យពេចន៍ឲ្យរឹងរឹតតែពីរោះគាប់ចិត្តជាកិយ្យាភាពឡើង ។ យើងមានសង្ឃឹមថា អស់លោក-អ្នក មុខជានឹងចុះឈ្មោះជាវទស្សនាវដ្តីកម្ពុជសុរិយា ក្នុងឆ្នាំ ១៩៥១ តទៅទៀត ហើយនឹងជួយផ្សាយដំណឹងអំពីប្រយោជន៍នៃទស្សនាវដ្តីយើង តៗ ទៅដល់បងប្អូនរួមជាតិដែលនៅជិតខាងជាពុំខាន ។

ឯរឿងរ៉ាវ ទាំងផ្នែកអក្សរសាស្ត្រទាំងផ្នែកសាសនា ដែលយើងយល់ឃើញថាមានប្រយោជន៍សំខាន់ដល់បងប្អូនរួមជាតិ ហើយបានគ្រោងទុកបំរុងនឹងបោះពុម្ពក្នុងឆ្នាំ ១៩៥១ ដូចមានកាយមាតិកា តទៅនេះ ៖

## ផ្នែកអក្សរសាស្ត្រ

១ – អក្សរសាស្ត្រខ្មែរ (គោលចារិកខាងផ្នែកអក្សរសាស្ត្រ ព្រមទាំងពាក្យកាព្យឃ្លោងចាស់ៗ ឬថ្មីទើបថ្មី) ។

២ – ព្រះរាជពង្សាវតារប្រទេសកម្ពុជា នៅមានបោះពុម្ពតទៅទៀត ។

៣ – ឯកសារ (រឿងរ៉ាវសំខាន់ៗ ដូចសិលាចារិកជាដើម) ។

៤ – រឿងសាមកុក នៅតែបោះពុម្ពតទៅទៀត ត្រាតែចប់ ។

៥ – វប្បធម៌ (ពាក្យបារាំងប្រែជាខ្មែររបស់គណៈកម្មការវប្បធម៌) ។

៦ – សុភាសិតផ្សេងៗ របស់ជាតិយើងនិងនានាជាតិ ។

៧ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ។

៨ – ទំនៀមទំលាប់ខ្មែរ របស់គណៈកម្មការទំនៀមទំលាប់ ។ល។

## ផ្នែកសាសនា

១ – ដំណើងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ។

២ – ធម្មទេសនា ដែលមានអត្ថរសប្លែកៗ ។

៣ – សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ – នឹងជ្រើសរើសប្រែរឿងក្នុងព្រះសូត្រខ្លះ ដែលជាផ្លូវប្រតិបត្តិ ។

## ប្រយោជន៍នៃទស្សនាវដ្ដីកម្ពុជសុរិយា

បងប្អូនរួមជាតិទាំងឡាយជ្រាបស្រាប់ហើយថា ទស្សនាវដ្ដីនិងសារពត៌មាន ក្នុងប្រទេសយើង មានមិនលើសពី ២-៣ ឈ្មោះ

ប៉ុណ្ណោះ ៗ ចំនួននេះបើយកទៅធៀបនឹងចំនួនទស្សនាវដ្ដី សារពត៌មាន ក្នុងប្រទេសគេជិតខាងប្រទេសយើង ឃើញថាខាងយើងតិចជាងគេឆ្ងាយណាស់ ស្ទើរតែរកប់ថាមាននឹងគេពុំបាន ៗ ខាងយើងដែលមានបញ្ញបករណ៍ទាំងនេះតិច មកពីយើងខ្មែរអ្នកស្ម័គ្រអានមានចំនួនតិចនាក់, ខាងគេដែលមានបញ្ញបករណ៍ច្រើន មកពីជាតិគេមានអ្នកចូលចិត្តអានច្រើន ៗ បញ្ញាដែលជាផលកើតមកអំពីការអានច្រើននឹងការអានតិចតែងអនុវត្តទៅតាមគ្នា គឺបើក្នុងប្រទេសណា មានអ្នកអានច្រើននាក់ក្នុងប្រទេសនោះ អ្នកចេះដឹងក៏មានច្រើន; បើអ្នកអានមានតិច អ្នកចេះក៏មានតិច ៗ ចំពោះរូបមនុស្សម្នាក់ ៗ ក៏មានន័យដូចគ្នា គឺអ្នកណាអានច្រើន អ្នកនោះចេះដឹងច្រើន, អ្នកអានតិច ចេះដឹងតិច, អ្នកមិនអានសោះ ក៏មិនចេះសោះ សមដូចបុរាណសុភាសិតថា "បើអានទោះតិចច្រើន នឹងចំរើនសត្វថ្ងៃទៅ ដូចឃ្មុំដប់ទឹកនៅ ផ្កាឈើក្រៅកក្កូមិបាន" ៗ ព្រោះថាទស្សនាវដ្ដី សារពត៌មាន ជាឃ្នាំងវិជ្ជា មានមុខការខាងបណ្ដុះដាំផ្សាំប្រាជ្ញានៃអ្នកអានឲ្យដើរទាន់សម័យ ៗ

មែនពិត ទស្សនាវដ្ដីយើងហើយនឹងអ្នកអាន ឈ្មោះថាឲ្យកម្លាំងផ្ដល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក ៗ តាមន័យនេះ ឃើញថាបងប្អូនរួមជាតិដែលចេញស្រាហ៊ុយជាវទស្សនាវដ្ដីយើង បានផលជា ៣ ចំណែក គឺ :

១ — ជួយទស្សនាវដ្ដីយើងឲ្យមានអាយុស្ថិតនៅយូរអង្វែង

២ — កាលអស់លោក-អ្នកបានអានហើយ នឹងកើតមានប្រាជ្ញាក្ដីស្មានក្នុងផ្លូវលោកផ្លូវធម៌

៣ — ផលជាកំពូល គឺអស់លោក-អ្នកនឹងមានកេរ្ដិ៍ឈ្មោះថាជាអ្នកតាក់ទឹកស្រោចដីឲ្យអក្សរសាស្ត្រខ្មែរយើង ដុះលូតលាស់ចំរើនទាន់កាលសម័យ ឲ្យមានទឹកមុខស្មើនឹងអក្សរសាស្ត្រនានាជាតិ ។

ហេតុនេះ សូមអស់លោក-អ្នកដែលមានបំណងជាវទស្សនាវដ្ដីយើងប្រចាំឆ្នាំ ១៩៥១ សូមផ្ញើឈ្មោះចុះនាមទីលំនៅនឹងប្រាក់ចំនួន ១៤៨ រៀល ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ក្នុងពេលឆាប់ៗ ។

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

Adresse:

M. le Secrétaire Général
de l'Institut Bouddhique
à Phnom-Penh

# ព្រះរាជក្រឹត្យ

# ក្រមទសភរិយា

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្តា (ចៅពញាសូរ) គ.ស. ១៦៩៣

## ហ្លួងនិពន្ធមន្ត្រី ញក-ថែម រួបរួម

(តទក)

---

បើចៅដែលគេថានោះ មានកំណាត់ចំណាំបានទូតឈ្នះឯកទូតទោទូតត្រីទូតនោះឲ្យយកអស់ទ្រព្យមកបែងជាភាគ ៣ ចោលភាគ ២ ឲ្យយកភាគ ១ ឲ្យចៅដែលកំណាត់ចំណាំគេជាដំពាក់សងរបស់ទ្រព្យ ដែលកំណាត់មកពិន័យចៅដើមក្តី ១ ជា ២ ហោង ។

មាត្រា ១. (សោត) ទោះអ្នកផងដំពាក់សារពើបំណុលនៃអ្នកផង បើម្ចាស់បំណុលនោះស្លាប់ នៅតែកំណាត់ចំណាំដំពាក់សារពើរបស់ទ្រព្យនៅ (នឹង) ចៅនោះ អានោះ នាងនោះ មេនោះ មានបងប្អូនកូនក្មួយចៅខ្មោចដែលស្លាប់នោះដឹងផងក្តី បានទៅទារគាលសន្ទូវឡើយ ប្រពន្ធចៅដែលដំពាក់បំណុលនោះដឹងផង នោះហៅថាសាក្សី ទើបឲ្យទារអំពីចៅនូវអាមេមានគួ បើគួប្រកែកថា ពុំមានដំពាក់អ្វីៗ ឡើយ ទើបប្រពន្ធកូនចៅបងប្អូនខ្មោចស្លាប់នោះប្តឹងចៅក្រម ឲ្យអាជ្ញាអ្នកកណ្តាលទៅប្រកោះគួដែលដំពាក់របស់ទ្រព្យគេនោះមកបង្គាប់ឲ្យគត់ពាក្យ ដោយដំណើរ បើរកទៅ (ឃើញ) ប្រាកដមែន ដូចគេប្តឹងហើយ ឲ្យលក់

សុរិលបង់ ៗ បើប្រាក់យកាយដំអម្ចាស់ទ្រព្យវិញស្លាប់ ឲ្យលក់សុរិលបង់ ហើយឲ្យរិបអស់ទ្រព្យរបស់ប្រពន្ធកូនជារេបិបហោង ៗ បើរបួសពុំពិការ សាគន់រូបរស់ពុំស្លាប់ឡើយ ឲ្យលក់ជាប់សុរិលហោង ឲ្យខ្ទុនភ្នាក់ងារ ហូតយកខ្ទាត់ព្រះឃ្លាំងព្រះគ្រិងហោង ៗ

មាត្រា ១ (សោគ) ទោះអ្នកជង់អន្ទង់ហោរក្តី បបួលហោរក្តីឲ្យ ទៅប្ញុទ្ធបាញ់ចាក់កាប់សម្លាប់គេនោះក្តី ទោះគេចាប់ហោរនោះបានក្តី បើ អាហោរកំសត្រគ្នាក្តី កំបបួលអន្ទង់គ្នាក្តី កំជាគេជួលក្តី ឲ្យទៅពញាបាញ់ ចាក់កាប់ ប្រើឲ្យចាប់កោះនាង់នោះអានោះមេនោះ ទើបឲ្យទៅក្រមឲ្យ អាជ្ញាអ្នកកណ្តាលទៅចាប់ដែលជួល ដែលបបួល (ហោរ) ប្រើមកកត់ ពាក្យនូវអស់ដំនុំហើយ ទើបឲ្យដំនុំពិចារណាពាក្យអាហោរ ប្រើនូវ អាហោរអន្ទង់នូវអាហោរបបួល នៅខ្លួនហោរដែលជួល បើដំនុំហើយ បាន ជាអន្ទង់ហោរក្តីអន្ទង់ខ្មោចក្តី ឲ្យលក់សុរិលបង់ ៗ បើប្រែកឲ្យចាប់ឆ្នោត បើបានទូតឈ្នះឯកទូតហើយ ចាញ់ទោទូតនូវត្រីទូត ឲ្យសង់ពេញប្រាកដ ជាហោរតាមព្រះច្បាប់ទោះបានទូតចាញ់ឯកទូតនៅត្រីទូត ឲ្យបែងទ្រព្យ នោះជាភាគ ៣ ភាគ ១ ទោល យកភាគ ២ មកឲ្យទៅដែលកំណត់ ចំណាំគេជាដំពាក់នោះ សង់របស់ទ្រព្យត្បូនោះហោង កុំឲ្យពិន័យឡើយ ដ្បិតឥតដំណឹងម្ចាស់ ៗ បើមានកំណត់ចំណាំខ្មោចដំពាក់សារពើទ្រព្យ របស់នូវហោរនោះ នូវអានោះ នាង់នោះ តែអស់បង់ប្អូនប្រពន្ធខ្មោចនោះ

ដឹងផង ហើយអស់បងប្អូនប្រពន្ធកូនទៅដែលកំណត់ចំណាំខ្មោចថាជំពាក់ នោះ គេពុំដឹងផងនោះឥតសាក្សី កុំឲ្យជឿកំណត់កត់ចំណាំនោះឡើយ ។

មាត្រា ១ (សោត) ទោះចោរហនេយ្យ ទោះបាញ់ចាក់កាប់សម្លាប់គេទឹងដាវទឹងលំពែង កាំភ្លើង ទឹងស្នាទឹងធ្នូ ទឹងសម ចង្រប់ ឈ្បុក មូល ស្នូរ កន្ទុរ បើពុំបានស្លាប់ប៉ុន្តែរបួសជាទម្ងន់ ពិការទឹងធ្វើព្រះរាជការពុំបាននោះទុកស្មើស្លាប់ ឲ្យរកចោរឯណាដែលបាញ់ចាក់កាប់គេនោះឲ្យសម្លាប់ហើយរឹបអស់របស់ទ្រព្យប្រពន្ធ (កូន) ថ្វាត់ថ្វាយហោង ។ បើអាចោរឯណាក៏ជាគ្នាទឹងអាចោរនោះ ឲ្យគេដើមក្តីប្តឹងឲ្យកោះចាប់មកជណ្តឹងពិចារណា បើវាប្រកែកថាទេ ពុំបានបាញ់ចាក់ ពុំបានលួចរបស់ទ្រព្យបង្អុលនោះ ឲ្យប្រកាន់ចាប់ឆ្នោត បើដើមក្តីបានត្រូវតឯកទូត បើចុងក្តីនូវចោរបានទោទូតនោះ ឲ្យយកទោទូតនូវត្រីទូតទុកជាស្មើគ្នា ឲ្យយកឯកទូតគេដើមក្តីជាឈ្នះ ហើយឲ្យយករបស់ទ្រព្យមកបែងជាភាគ ៣ ភាគ ១ ចោល យកភាគ ២ ឲ្យសងគេហោង ឲ្យខុនភ្នាក់ងារកាត់ថ្លៃទ្រព្យរបស់ ១០ យក ២ ឯខ្វាត់ស្នូកគោងទ្រពង់នោះឲ្យហូតយកគម្ងឹង ៣ ដ្បិតមុខងារចូលគ្នាហោង (១) ។

មាត្រា ១ (សោត) ទោះអ្នកផងធ្វើសាលាលើកខ្មោច ទោះនាហ្មឺន ជំទាវ នាងខុនណាង នូវបារគូបុរោហិតបែងសាលាត្រឹះទោះខុន ១ ភ្នាក់ងារហូតយក (ខ្វាត់) ថ្វាត់ថ្វាយគម្ងឹង ១២ សាលាសំរាំ

តម្លឹង ៤ ធ្វើពជដ្ឋបទ្រោបង់កល់ផ្ទាល់ដីឲ្យយកតម្លឹង ៧ ធ្វើជាពនឲ្យយកតម្លឹង ៦ ។ បើបានប្រាប់ តម្លឹង . . . ក៏បាន បាទ ៦ ក៏បាន បើផ្គាន អាកាសសាលានាំជាផ្លូលជាន់ធ្វើនោះ ពុំបានប្រាប់ ឲ្យយកក្រយាពិន័យអំពីអាដែលផ្លូលមកបែងយកតាមផ្លូបអាចោរម្រឹត ឯក្រយាពិន័យអាចោរដណ្តឹងផ្លូលនោះទុកស្មើប្រើចោរហោង ឲ្យខុនក្អាក់ងារហូតខ្វាត់មុខងារតម្លឹង ៣ យក (ដាក់) ព្រះឃ្លាំងព្រះគ្រឹងហោង[២] ។

មាត្រា ១ (សោត) នរអ្នកផងឈ្មោះគ្នាប្រព៌យគ្នាទឹងដំបងឈើឬស្សីដល់ជាំដាម នោះពិន័យតម្លឹង ១២ ដើងកោះស្លឹង ១០ ខុនក្អាក់ងារហូតខ្វាត់តម្លឹង ៣ ឯខ្វាត់ព្រះឃ្លាំងព្រះគ្រឹងហោង ។ បើខ្ញុំគេនឹងខ្ញុំគេឈ្មោះប្រព៌យព៌យគ្នាដល់ជាំដាម ឲ្យយកខ្វាត់បាទ ៦ ដើងកោះបាទ ៤ និមួយខ្លួនហោង[៣] ។

មាត្រា ១ (សោត) នរអ្នកផងសាហាវដេរប្រពន្ធកូនគេ ឲ្យពិន័យតម្លឹង ១២ ដើងកោះស្លឹង ១០ ខុនក្អាក់ងារហូតខ្វាត់តម្លឹង ៣ ព្រះឃ្លាំងព្រះគ្រឹងហោង ។ បើស្រីដេរប្រុសតម្លឹង ៦ ដើងកោះស្លឹង ១០ ឲ្យខុនក្អាក់ងារហូតយកខ្វាត់បាទ ៦ ហោង ។

មាត្រា ១ (សោត) ទោះអ្នកផងស្ងួនអន្ទករនឹងគ្នា បានកូន ១ ក្តី

---

១-២-៣ ទាំងប៉ុន្មានមាត្រានេះ មិនសមរាប់បញ្ចូលក្នុងក្រមទសភរិយាទេ ព្រោះនិយាយតែអំពីរឿងចោរខ្ទួយឬឈ្មោះទាស់ទែងវាយដំគ្នា ។

កូន ២ គ្គី (ហើយ) ប្រែលែងលែងគ្នាវិញ ឲ្យយកខ្វាត់បាទ ៦ ដើង កោះស៊ឹង ១០ និមួយត្បូហាង ។

មាត្រា ១ (សោត) នរូស្រីឈ្មោះគ្នាដេរវ៉ាយក្រៅជាំជាមនោះ ឲ្យពិន័យតម្លឹង ១២ ដើងកោះស៊ឹង ១០ ។ បើឈ្មោះប្រែកែកដេរ តែពុំបានវ៉ាយគ្នាជាំជាមនោះ ឲ្យពិន័យតម្លឹង ៦ ដើងកោះស៊ឹង ១០ ខុនក្អាក់ង៉ារហូតខ្វាត់បាទ ៦ ហោង ។

មាត្រា ១ (សោត) ទោះប្រុសផងបងកស្លាប់នោះ ឲ្យខុនក្អាក់ង៉ារ កោះយកអ្នកដែលនៅជាមួយនឹងអ្នកបងកឯង មកដណ្ដឹងពិចារណារក បើឥតទោស បងកស្លាប់ខ្លួនឯងនឹងខ្សែល្ហ៊ ឲ្យខុនក្អាក់ង៉ារហូតយកខ្វាត់ អំពីកូនប្រពន្ធបងប្អូនដែលនៅជាមួយតម្លឹង ៣០ ។ បើរកទោសឃើញ ជាអានទោសមែន ឲ្យយកដញ្ញាំង ៣ ថ្វាត់ថ្វាយ បើបងកនឹងសំពត់ អម្បោះ សូត្រ ព្រែ ខ្សែព្រាលនោះ បូលមុខង៉ារឲ្យ (យក) ខ្វាត់ ដើមឈើតម្លឹង ៣ នូវដើងកោះស៊ឹង ១០ ហោង ។ បើស្រីបងកស្លាប់ នឹងខ្សែល្ហ៊ ឲ្យខុនក្អាក់ង៉ារយកដឹង ៧ តម្លឹង ៤ បើរកទោសឃើញ ជាមានទោសមែនអំពីអ្នកដែលនៅ ។ បើឥតទោសហើយបងកនឹងខ្សែព្រាល អម្បោះ សូត្រព្រែនោះ ឲ្យខុនក្អាក់ង៉ារហូតយកខ្វាត់ ដើមឈើបាទ ៦ នូវដើងកោះស៊ឹង ១០ ហោង ។

មាត្រា ១ (សោត) ទោះប្រុសប្ដីដេរប្រពន្ធសាហាវទឹងចិត្តឥត ទោសឥតគុំនាប់នោះ ឲ្យខ្ទុនក្ដាក់ងាររហូតយកខ្វាត់តម្លឹង ៣ ដើងកោះស្លឹង ១០ ហោង ។ បើស្រីប្រមាថប្ដីឥតទោសឥតគុំនាប់ ឲ្យហូតខ្វាត់តម្លឹង ៥ ដើងកោះស្លឹង ១០ ហោង ។

មាត្រា ១ (សោត) ទោះស្រីដង់ប្រណោះប្រព័យដេរព័យគ្នាដណ្ដើម ប្ដីដណ្ដើមសង្សារ បើប្រាកដមែនជាលួចប្ដីលួចសង្សារគ្នាមែន ឲ្យយក កាំបិតស្នានូវអម្បែងបាន ប៉ុមុខប៉ុទ្រោង បើលោះកាំបិតស្នានូវអម្បែង បានជាប្រាក់តម្លឹង ៥ នូវដើងកោះស្លឹង ១០ ។ បើពុំប្រាកដជាបោរជា សាហាយ ទោះស្រីសាហាយដេរទឹងអំណាចឲ្យពិន័យជាប្រាក់តម្លឹង ១២ ដើងកោះស្លឹង ១០ និមួយខ្ទុនហោង ឲ្យខ្ទុនក្ដាក់ងាររហូតយកខ្វាត់ តម្លឹង ៣ និមួយគួ ព្រះយ៉ាំងតម្លឹង ៦ បាទ ១ ថ្វាត់ថ្វាយហោង ។

មាត្រា ១ (សោត) នរអ្នកផងប្រលែងលែងគ្នាក្ដី លួចប្រពន្ធគេ ពុំបាននាំរត់ក្ដី ទោះកាបទឹងកូនក្រមុំគេទឹងខ្ញុំគេពុំបាននាំរត់ក្ដី ទោះកាប ហើយបាននាំរត់ក្ដី បើមានមេអណ្ដើកមេនាំការប្រពន្ធគេកូនក្រមុំគេខ្ញុំគេក្ដី នោះត្រូវក្រយាពិន័យអាប្រុសនូវមេស្រីដំកាបនោះ ត្រីគុណចតុគុណ ត្រូវមេអណ្ដើកមេនាំការភាគ ៨ បើជួយនាំរត់នោះភាគ ៧ បើមានគេ ឲ្យលាក់បំពួននៅផ្ទះនៅព្រៃក្ដី នោះត្រូវភាគ ៦ បើឲ្យអង្ករស្បៀងស្ងាម្ប នោះត្រូវភាគ ៥ ត្រូវអាប្រុសភាគ ១០ ។ (មា៩៨)

## សព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

## លោកមិញ - ឆាគ្រី រូបរូម

(តមក)

Simple (un homme simple) = សាមញ្ញ, កបសា

Simplicité = សេចក្តីកបសា

Emancipation = អត្តាធិនភាព (ការផុតពីអាណាព្យាបាល)

Libération = សេរីភា

Chancelier = សង់សឺលីយេរ

Pionnier = អ្នកត្រួសត្រាយ

Clergé = សហធម្មិក (បព្វជិតដែលប្រព្រឹត្តធម៌ត្រៃគា)

Reportage = ការយកពត៌មាន

Faveur = អនុគ្រោះ

Avis favorable = យោបល់យល់ព្រម

Temps opportun = កាលគួរ

inopportun = កាលពុំគួរ

Diabète = មធុមេហរោគ (រោគទឹកមូត្រផ្អែម)

Corp franc khmer = កងឯកទេសខ្មែរ

Ridicule = ដែលគួរសើចចំអក

Scrupule = កាសង្កា (សេចក្ដីរង្កៀសចិត្ត)

Remords = វិប្បដិសារ (សេចក្ដីស្ដាយក្រោយ)

Le Repentir = វិប្បដិសារ (សេចក្ដីស្ដាយ, មមៃ, ក្រោយ)

Le Rendez-Vous = ការណាត់ជួបគ្នា, ទីណាត់ជួបគ្នា

11 — 10 — 49

Caprice = កបចិត្ត, ចិត្តសាក់

Echéance = ថ្ងៃសងបំណុល, ឥណប្រតិទាន

Scène = ឈុត, វិការដ្ឋាន

Classement annuel = ការចាត់ថ្នាក់ប្រចាំឆ្នាំ

Classement hebdomadaire = ចាត់ថ្នាក់ប្រចាំសប្ដាហ៍

25 10 49

Commandant du Secteur Sud = អ្នកបញ្ជាការផ្នែកទក្សិណ

— du Quartier — — សង្កាត់

— du sous Quartier — — សង្កាត់រង

Vigilance = អប្បមាទ

Négligence = សេចក្ដីប្រមាទ

Maltraiter = ធ្វើទុក្ខ, ធ្វើបាប

Offense - ការប្រមាថ

Escadron = អស្វានីក

Torturer = ធ្វើទារុណកម្ម

28 10 – 49

Fragment = បំណែក, ផ្នែក

Fragments de la pièce = ផ្នែករឿងល្ខោន

Pièce en un acte = រឿងល្ខោនក្នុងឆាកមួយ

Biographie = ជីវប្រវត្តិ

Table des matières = បញ្ជីមាតិកា, បញ្ជីរឿង

A cause de = ដោយ ឬ ព្រោះហេតុតែ

Au profit de = ជាកំរៃដល់, ជាប្រយោជន៍ដល់

Au détriment de = ជាការនាំឲ្យ ខូច

8–11–49

Artiste = សិល្បករ

Beaux-Arts = វិចិត្រសិល្ប

Ministère des Beaux-Arts = ក្រសួងសិល្បការ

Contre-seing = ហត្ថលេខាអម

Contresigner = ចុះហត្ថលេខារង

Adaptation = ការយកលំនាំ

Imitation = តម្រាប់

Imiter = ត្រាប់

Expédition des Affaires courantes. កិច្ចបាត់ការសាមញ្ញ

15 – 11 49

Populaire = ប្រជាមានិត, សាមញ្ញ

Requérir = ប្ដឹងតក៏

Requérant = អ្នកប្ដឹងតក៏

Suggérer = ឲ្យយោបល់, ណែនាំ

Suggestion = ការឲ្យយោបល់, ការណែនាំ

Leçon = មេរៀន

18—11—49

Observer កត់សំគាល់, សង្កេត, កាន់, ប្រព្រឹត្ត

Observation = កំណត់សំគាល់, ការសង្កេត, ការកាន់, ការប្រព្រឹត្ត

Internat = អន្តេវាសិកភាព

Externat = ពហិវាសិកភាព

Forfait = ការម៉ៅផ្ដាច់

Forfaitaire = ដែលម៉ៅផ្ដាច់

Sacrifice = ពលិកម្ម

Sacrifier = ធ្វើពលិកម្ម

22 11–49

Disposition = បទបញ្ញត្តិ

Principe = គោលការណ៍

Candidature = បេក្ខភាព

Charte = ធម្មនុញ្ញ

25–11–49

Le contrôle de l'Immigration = ក្រមត្រួតត្រាជនចូលស្រុក

Prérogative = បុព្វសិទ្ធិ

Modalité = បែបបទ

Compétence = សមត្ថកិច្ច, សមត្ថកម្ម, សមត្ថភាព

Des hautes parties contractantes = ឧត្តមភាគីគូសញ្ញា

Etendue = វិសាលភាព

Coordonner = សម្របសម្រួល

Règlementer = ដាក់បទបញ្ជា

Service des transmissions = ក្រមនាំសារ

Plan d'équipement = ផែនការណ៍សម្ភារបរិក្ខារ

Transfert = ការផ្ទេរ

26–11–49

(មានត)

# រឿងៈព្រងក្មា

# លោក សាង - សាវ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

---

ថាហើយនាងនៅស្ងៀមទទួនមុខកើតទុក្ខយ៉ាងខ្លាំង ៗ លុះនាងជូជាម៉្ហាសារ៉ាជាកូនលោករដ្ឋមន្ត្រីព្រុងបោះហើយ ក៏នឹកក្នុងចិត្តថាៈ "ខ្ញុំអញយល់ហើយ ស្រីនេះក្បត់ចិត្តប្តីទេតើ ប៉ុន្តែស្រីនេះស្តាយក្រោយពន់ពេក" ៗ នាងទើបឲ្យស្រីនេះចេញពីកន្លែងនោះទៅ ហើយបានពោលពាក្យគួរសមរកពីរបីមាត់ផង. រួចទើបត្រាប់ឲ្យស្មៀនរបស់នាងសរសេរសេចក្តីដែលនាងបានពិភាក្សាជាមួយជនម្នាក់ៗ ដែលយើងបាននិទានមកហើយនេះ ៗ លុះកាលណាឪពុករបស់នាងបានស្តាប់សេចក្តីសព្វគ្រប់ហើយ លោកមានចិត្តត្រេកអរជាពន់ពេក ហើយបាននាំកូនក្តីទាំងអស់ទៅគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយសារលោកបានប្រាប់ការពិតអំពីមាត់អ្នកដែលមានទោសទាំងពីរ ៗ

ព្រះករុណាទ្រង់ចេញព្រះរាជក្រឹត្យមួយតាមពាក្យដែលនាងជូជាម៉្ហាសារ៉ាបានរៀបចំជាមុននោះដូច្នេះថា "ឃ៉ាយតាដែលមិនមែនប្តីនោះហើយដែលរៀបនឹងក្បត់ចិត្តនាងជាសហាយ ត្រូវទោសដល់ស្លាប់ខ្លួន, តែប៉ុន្តែដោយអញការុណិត អញលើកទោសនេះឲ្យ, ឲ្យរត់ចេញពីព្រះរាជធានីកុំ

បន្ទន់ឡើយ, ឯកូនប្រុសរបស់មហាសេដ្ឋីដែលឥតគិតដល់ទ្រព្យសម្បត្តិ ហើយដែលមិនចេះក្បត់កិច្ចសន្យានោះគឺជាប្តីរបស់នាងពិត, បុរសរូបនេះមានកិរិយាគួរឲ្យសរសើរគ្រប់គ្នា; ឯចំណែកខាងនាងកំលោះដែលយំសោកនៅមុខអញនេះត្រូវទោសសំឡាប់ដែរ ព្រោះបានធ្វើឲ្យឈ្មោះប្តីរបស់ខ្លួនអាប់អោនជាពន់ពេក, ប៉ុន្តែប្តីនាងនេះអភ័យទោសឲ្យ, អញក៏អត់ទោសឲ្យដែរ ព្រោះនាងនេះបានប្រាប់ការពិត ដល់បុត្ររបស់លោករដ្ឋមន្ត្រី ដោយបាននិទានយ៉ាងក្បោះក្បាយអំពីផ្លែឈើទុំដែលមិនអាចភ្ជាប់ទៅកន្លែងដែលជ្រុះវិញ នឹងអំពីកូនក្មេងដែលមិនអាចចូលទៅក្នុងផ្ទៃមាតាវិញបាន, នេះជាដំបូន្មានរបស់ក៏ទៅថ្ងៃក្រោយទៀតឥឡូវនេះអញឲ្យរួចខ្លួនបុះ" ។

ក្នុងពេលនោះ ទេវតាដែលរក្សាស្វេតច្ឆត្រៃស្រែកជយោឡើងដោយការបានឮព្រះអង្គមានព្រះបន្ទូលដូច្នោះ ។ ឯព្រះករុណាក៏ទ្រង់លើកកូនស្រីនៃលោករដ្ឋមន្ត្រីជាអគ្គមហេសី ដោយសារនាងបានប្រើប្រាជ្ញាយ៉ាងអស្ចារ្យក្នុងរឿងនេះ ។

សុភាពបុរសទាំងឡាយ ! អ្នកគោរពធ្វើអន្តេគឲ្យយ៉ាងម៉ត់ចត់ដូចនាងធូជាម៉ាសារី ក្នុងការលួចប្លន់, ការបោកប្រាស់ ឬក្នុងការក្បត់ចិត្តដែលគេបញ្ចូនសំណុំរឿងដល់សាលារបស់អ្នក; គោរពអ្នកបំភ្លឺឲ្យច្បាស់យ៉ាងប្រសប់ដូច្នេះហោង ។

## ៧ – ជាងស្បែកជើង និង អ្នកបោកខោអាវ

" បាចធូលីឈរលើទួលប្រាសខ្យល់
ធូលីវិលបោរមកដល់អ្នកបាចវិញ
អ្នកឈ្នានិះរះឲ្យគេកើតទុក្ខម្នេញ
ទុក្ខនោះបេញកើតមានពេញអ្នកឈ្នានិះ "

សេចក្តីឈ្នានិះព្យាបាទឲ្យគេមានទុក្ខ នឹងនាំឲ្យខ្លួនមានទោសទុក្ខវិញ ដូចមានរឿងជាងស្បែកជើងតទៅនេះ:

ក្នុងកាលដ៏កន្លងទៅយូរអង្វែងហើយ ក្នុងសាសនាព្រះពុទ្ធព្រះនាម ធូមិយ័ទ: "Thourmayda" បានជាងស្បែកជើងម្នាក់ តាំងទីលំនៅនាមាត់ទន្លេគង្គាជិតផ្ទះអ្នកបោកខោអាវម្នាក់ ដែលមានកេរ្តិ៍ឈ្មោះល្អក្នុងទីនោះ ។ អ្នកបោកខោអាវនេះ ជាមនុស្សធ្វើការល្អ មានចិត្តសុភាពរាបសា អ្នកផងទាំងពួងតែងមកទិញដូរផ្ទះគាត់ច្រើនណាស់ ។ គាត់ជាអ្នកមានទ្រព្យ ហើយរស់នៅយ៉ាងប្រសើរផង ។ ចំណែកជាងស្បែកជើងវិញ មិនសូវមានធនធានទេ ហើយមានចិត្តប្រស្សាច្រណែននិន្ទានឹងអ្នកបោកខោអាវយ៉ាងខ្លាំង ។ នៅថ្ងៃមួយ ដោយឥតគិតវែងឆ្ងាយ ជាងស្បែកជើងសុខចិត្តបំបែកសេចក្តីមេត្រី ដែលមានទាក់ទងជាយូរអង្វែងណាស់មក ហើយរកនឹករូបគាត់នឹងជាងបោកខោអាវ, គាត់នឹកថាធ្វើដូច្នោះគ្មានទាស់ខុសអ្វីទេ ។

ឯចំណែកអ្នកបោកខោអាវវិញ គិតតែខំប្រឹងធ្វើការប្រព្រឹត្តល្អជានិច្ច ហើយគ្មានចាប់ក្តីកនឹកនានឹងអំពើដែលជាងស្មូនឆ្នាំងប្រព្រឹត្តនោះសោះ ។ គាត់រស់នៅជាសុខសប្បាយដូចធម្មតា ។ ជាងស្មូនឆ្នាំងមានគំនិតចង់ចាក់រុកអ្នកបោកខោអាវ: គាត់គិតថាគោងតែឲ្យទឹកប្រម៉ាត់គួសត្រូវរបស់គាត់នេះបែកធ្លាយដោយហេតុណាមួយ ។ លុះគិតយ៉ាងដូច្នោះហើយគាត់ក៏ឡើងទៅគាល់ស្តេចផែនដី ដែលជាក្សត្រិយ៍មួយ មានព្រះហឫទ័យក្លាហាន ប៉ុន្តែមិនឈ្លាសវៃទេ ។ ជាងស្មូនឆ្នាំងក្រាបទូលថា "ដំរីរបស់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ជាដំរីពណ៌ខ្មៅសុទ្ធ ប៉ុន្តែទូលព្រះបង្គំដឹងជាក់ថា: អ្នកបោកខោអាវដែលជាអ្នកនៅជិតខាងទូលព្រះបង្គំ អាចបេះផ្ទៃដំរីឲ្យមានពណ៌ផ្សេង ៗ បាន, បើសិនណាព្រះករុណាមានព្រះរាជឧង្ការត្រាស់បង្គាប់អ្នកបោកខោអាវនោះតែមួយព្រះឧស្ឋ មុខជាបានដំរីស ដូចឈ្មោះ ស៊ិនប៊ីអូស៊ិន "Tsinbiouslin" ពុំខាន ។

ដែលជាងស្មូនឆ្នាំងក្រាបទូលដូច្នោះ ឥតបានគិតថា ព្រះករុណាមានព្រះហឫទ័យចង់បានដំរីសនោះឡើយ ប៉ុន្តែគាត់នឹកថា មុខជាស្តេចទ្រង់បង្គាប់ឲ្យជាងបោកខោអាវធ្វើតាមពាក្យញុះញង់របស់គាត់ពុំខាន, រួចគាត់នឹកទៀតថាទៀងតែជាងបោកខោអាវនេះ នឹងធ្វើដំរីខ្មៅឲ្យទៅជាដំរីសពុំកើតទេ: កាលបើដូច្នេះ ជាងបោកខោអាវមុខជាត្រូវទោស ហើយលែងមានអ្នកចូលទិញដូរក្នុងផ្ទះប្រជិនទៀតពុំខាន, តទៅគាត់នឹងបានសុខសប្បាយដោយសារជាងបោកខោអាវចុះក្រ ។

ព្រះរាជាកាលទ្រង់ស្ដាប់សព្វសេចក្ដីហើយ, ដំបូងស្ដេចទ្រង់ងឿងឆ្ងល់ជាពន់ពេក ហើយទ្រង់អស់សំណើចផង, ប៉ុន្ដែយូរបន្ដិចមកបែរជាមានព្រះហឫទ័យចង់បានដំរីសមួយ ។ ស្ដេចទ្រង់នឹកថា ជាងស្មូនថ្នាំងប្រហែលជានិយាយតាមហេតុពិតមែន បើអញគិតឲ្យជ្រៅទៅគួរតែល្បងមើល ព្រោះមិនជាការណ៍ចាស់ខុសខាតខូចអ្វីទេ ។

ឃើញទេ! ស្ដេចអង្គនេះ ជាក្សត្រិយ៍មួយគ្មានប្រាជ្ញាបន្ដិចសោះ ៗ ដោយឥតគិតវែងឆ្ងាយ ព្រះរាជាក៏ទ្រង់បង្គាប់ឲ្យគេទៅហៅអ្នកបោកខោអាវមក ហើយទ្រង់ត្រាស់ឲ្យជាងនេះធ្វើដំរីព្រះអង្គឲ្យស ។

ដំបូងអ្នកបោកខោអាវចង់អស់សំណើចនឹងស្ដេចដូចអ្នកផងទាំងពួង, រួចចង់ទូលព្រះអង្គឲ្យបានជ្រាបថា "រឿងរ៉ាវបែបនេះ ល្អមើលណាស់ ហេតុម្ដេចក៏ព្រះអង្គមានព្រះបន្ទូលយ៉ាងដូច្នោះ", ប៉ុន្ដែដល់ឃើញព្រះភក្ត្រព្រះអង្គស្មើ, គាត់ក៏នឹកថា "ស្ដេចអង្គនេះកាចហើយល្ងង់ផង, ហេតុដូច្នោះគោងតែគាត្មាអញនៅស្ងៀមវិញ រួចធ្វើបុក្សបែបនឹងធឹងផង" ។ លុះបានដឹងថា នាយស្មូនថ្នាំងជាអ្នកនាំរឿងនេះមកទូល, គាត់បែរមុខមើលទៅអ្នកស្រុកទាំងពួងដែលចាំស្ដាប់ ហើយនិយាយថា: "សូមទ្រង់ព្រះមេត្ដាប្រោស! ទូលព្រះបង្គំនឹងចំប្រឹងខ្នះខ្នែងធ្វើតាមព្រះបន្ទូលឲ្យបាន, ប៉ុន្ដែសូមព្រះអង្គជ្រាបថា: កង្កិច្ចការរបស់ទូលព្រះបង្គំត្រូវយករបស់ដែលគេចង់ធ្វើឲ្យសនោះ ទៅជ្រលក់ទឹកមួយស្របក់ក្នុង

ផើងមួយដែលមានសាប៊ូ រួចអំពីនោះទៅទូលព្រះបង្គំដុសសំអាតឲ្យស, អាស្រ័យហេតុនេះ ទូលព្រះបង្គំត្រូវលាងដៃព្រះអង្គយ៉ាងដូច្នោះដែរ; ប៉ុន្តែធ្វើម្តេចទៅ បើទូលព្រះបង្គំគ្មានផើងណាឲ្យធំល្មមនឹងធ្វើការនេះ" ។

ព្រះរាជាមិនបានគិតវែងឆ្ងាយទេ ទ្រង់ឈ្វេងយល់ថា: មានតែជាងស្មូនឆ្នាំងទើបអាចធ្វើផើងបែបនោះបាន, ទ្រង់ក៏ត្រាស់ហៅជាងស្មូនឆ្នាំងមក ហើយទ្រង់មានព្រះបន្ទូលថា: "នាយស្មូនឆ្នាំង! យើងព្រមធ្វើតាមពាក្យរបស់អ្នក ដើម្បីឲ្យដៃយើងមានពណ៌សឡើង, ប៉ុន្តែមុននឹងធ្វើការនេះ អ្នកបោកខោអាវត្រូវការផើងមួយយ៉ាងធំ ដើម្បីជ្រលក់ដៃនោះ. ហេតុដូច្នេះ យើងបង្គាប់ឲ្យអ្នកធ្វើផើងមួយឲ្យយើង" ។

ជាងស្មូនឆ្នាំងលុះបានឮព្រះបន្ទូលយ៉ាងដូច្នោះ ក៏តក់ស្លុតយ៉ាងខ្លាំង ។ ម្តងគាត់គិតថា កុំខ្លាចស្តេចក្រោធ ត្រូវទូលព្រះអង្គតាមដំណើរទៅ, ប៉ុន្តែគាត់មានចិត្តឈ្នានិះជាពន់ពេក ទើបគាត់សម្រេចថាត្រូវតែល្បងធ្វើផើងតាមព្រះបន្ទូលឲ្យទាល់តែបាន ។ គាត់ទៅពឹងពាក់មិត្តនឹងក្រុមញាតិរបស់គាត់ទាំងអស់ ។ គាត់ប្រមូលដីឥដ្ឋបានជាច្រើន ទុកគរក្នុងសួនច្បាររបស់គាត់ រួចគាត់ខំប្រឹងធ្វើបានផើងមួយយ៉ាងធំ អស់ពេលជាចំនួនច្រើនថ្ងៃ ។ គាត់យកផើងនេះទៅថ្វាយព្រះករុណា, ព្រះអង្គមានព្រះហឫទ័យរីករាយជាខ្លាំង ហើយទ្រង់ប្រគល់ផើងនោះឲ្យទៅអ្នកបោកខោអាវយ៉ាងប្រញាប់ ។ ឯអ្នកបោកខោអាវ

ក៏យកផើងនោះទៅដាក់ទឹក ដាក់សាប៊ូជាច្រើន ហើយក្រាបទូលថា រួចស្រេចអស់ហើយ ។ ក្រោយមក ពួកកងសេនាក៏នាំសត្វដ៏ស្អុតនោះមកដល់ ។ ឯទ្រម៉ក់បាននាំដំរីចូលទៅ ។ ដំរីគ្រាន់តែដាក់ជើងបន្តិចទៅក្នុងផើង ។ ក៏បែកខ្ចាយជាមួយពាន់បំណែក ។

គេបាននាំរឿងនេះទៅក្រាបទូលព្រះករុណា ជាម្ចាស់ជីវិតលើត្បូង, ព្រះរាជាទ្រង់បានត្រាស់បង្គាប់ឲ្យជាងស្មូនឆ្នាំងធ្វើផើងមួយទៀត ។ ឯផើងទី ២ នេះក៏បែកខ្ចាត់ខ្ចាយទៀត, រួចផើងទី ៣, ផើងទី ៤ និងផើងជាច្រើនទៀត ដែលទទួលព្រេងសំណាងដូចផើងមុន ៗ ។

ជួនកាលផើងដែលធ្វើថ្មីនោះក្រាស់ពេករកដាំទឹកឲ្យពុះពុំកើត ជួនកាលផើងនោះស្តើងពេក ដំរីគ្រាន់តែដាក់ជើងលើបែកខ្ទេចខ្ទី ។ ជាងស្មូនឆ្នាំងលុះខំធ្វើការដ៏លំបាកនេះរាល់ថ្ងៃទៅ ក៏ចាយទ្រព្យខ្ជះខ្ជាយឡើង ៗ ទាល់តែខាតលិចលង់គ្មានសល់អ្វីសោះ ។ គាត់មុខជាស្លាប់ដោយអត់ឃ្លាន បើសិនណាអ្នកបោកខោអាវដែលមានចិត្តដ៏ប្រសើរខ្ពង់ខ្ពស់ មិនជួយទាំងមិនហុចដៃដើម្បីផ្សះផ្សារឿងនេះ ។

ជាងស្មូនឆ្នាំងយកខ្លួនឯងទៅលអន្ទាក់ នេះគឺចង់បោកគេ រួចត្រូវគេបោកវិញ ។ មានមនុស្សជាច្រើន ដែលមានគំនិតអាក្រក់ ចង់បំផ្លាញគេ ហើយក្រោយមកដឹងខ្លួនថា បាបកម្មនេះត្រឡប់មកលើខ្លួនឯងវិញ ។ នេះជាសេចក្តីវិនិច្ឆ័យប្រកបដោយសុចរិតយុត្តិធម៌មួយយ៉ាង

ស្តែងណាស់ ៗ ដូច្នេះយើងទោះបីក្រ ឬលំបាកយ៉ាងណាក៏ដោយ យើងមិនត្រូវចិញ្ចឹមចិត្តឈ្នានិះនឹងអ្នកឯទៀត ដែលរស់នៅគ្រាន់បើជាងយើងទេ, តោងយើងចៀសវាងអ្នកណាដែលមានទុក្ខដោយការប្រព្រឹត្តអំពើប្រណែនដ៏អាក្រក់នេះ; នៅនាលោកិយនេះមនុស្សម្នាក់ ៗ សឹងមានវាសនាទាបខ្ពស់ខុសគ្នាតែរៀងខ្លួន ជួនកាលវាសនានាំឲ្យសប្បាយ ជួនកាលនាំឲ្យទុក្ខ, ឯចំណែកទ្រព្យដែលមនុស្សយើងត្រូវប្រាថ្នាហើយជាទ្រព្យជិតជាប់តាមខ្លួនទៅអនាគតជាតិទៀតបាននោះគឺ: ការប្រព្រឹត្តជាសុចរិត យុត្តិធម៌ ៗ

(មា[illegible]ត)

អង្គរបស់អ្នកជំនួញ

បញ្ញា, ឧស្សាហ៍, ការគប់មិត្តៈ
អ្នកជំនួញគួរគិតឲ្យមានឡើង
គុណ ៣ ប្រការនេះឆាប់ចំរើន
ភោគៈច្រើនឡើងជានិរន្តរ៍ ។

យូរ-អ៊ុង

ភាគទី ៧

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯអង់អ៊ុននោះ លុះបានឃើញលីប៉ោមកកេដល់ផ្ទះហើយ ទើបចេញទៅទទួលឲ្យចូលមកនិយាយការទាន់ក្នុងល្វែងផ្ទះ ហើយឲ្យលើកអាហារមកបរិភោគជាមួយគ្នា ៗ លុះបរិភោគរួចស្រេចហើយ លីប៉ោជំពបថា ខ្លួនខ្ញុំបាទគ្រាន់តែជាទីនាយអាហានមហាឧបរាជ ចំណែកលោកជានាហ៊ុនមានបណ្ដាស័ក្ដិធំក្នុងហាន ហេតុម្ដេចបានជាលោកឲ្យយករបស់ទៅឲ្យខ្ញុំបានល្អម្ល៉េះ ? ខ្ញុំបាទជាអ្នកតូចមិនគួរលោកពប់អានដល់ប៉ុណ្ណោះទេ ៗ អង់អ៊ុនតបថា សព្វថ្ងៃនេះ ខ្ញុំសំឡឹងមើលក្នុងទីក្រុងនឹងខែត្រក្រៅទាំងអស់ នឹងរកអ្នកឯណាឲ្យខ្លាំងពូកែស្មើនឹងអ្នកគ្មានសោះ ខ្ញុំឲ្យរបស់នេះ

ព្រោះស្រឡាញ់ថ្មីដៃអ្នកកុងការទាហាន ។ លីប៉ោបានស្តាប់ក៏មានសេចក្តីត្រេកអរណាស់ ។ អង់អ៊ុនចាក់ស្រាគំនាប់លីប៉ោ ហើយនិយាយបញ្ជោរសរសើរលីប៉ោជាអនេកប្រការ ទើបបណ្តេញមនុស្សបំរើឲ្យដើរចេញអស់ នៅសល់តែពួកស្រីបំរើ ៤ នាក់ ។ អង់អ៊ុនប្រើស្រីនោះឲ្យទៅហៅនាងតៀវសៀនចេញមក, ស្រីបំរើ ២ នាក់ក៏ចូលទៅអញ្ជើញនាងតៀវសៀន ហើយហែហមចេញមក ។

លីប៉ោឃើញនាងតៀវសៀន មានរូបភាពទឹងដំណើរញ៉ែងញ៉ង់ស្រស់ល្អណាស់ អត់ទ្រាំមិនបានក៏សួរអង់អ៊ុនថា នាងនេះជាកូនអ្នកឯណា? ។ អង់អ៊ុនប្រាប់ថា " នាងតៀវសៀននេះជាបុត្ររបស់ខ្ញុំ, សព្វថ្ងៃនេះខ្ញុំបានសេចក្តីសុខនៅធ្វើរាជការបាន ដោយបុណ្យអំណាចមហាឧបការទឹងអ្នក ។ ក៏មានសេចក្តីពប់អានមេត្តាដល់ខ្ញុំដូចសាច់ញាតិជាប្រាកដ ហេតុនេះទើបខ្ញុំឲ្យហៅបុត្រខ្ញុំចេញមក ដោយសេចក្តីប៉ុនប៉ង់ទឹងលើកជូនអ្នកឲ្យធ្វើជាភរិយា ដើម្បីទុកជាទីបញ្ចាំចិត្តដោយស្មោះត្រង់ " ថាហើយបង្គាប់នាងតៀវសៀនឲ្យចាក់ស្រាគំនាប់លីប៉ោ ។

ឯនាងតៀវសៀនបានចាក់ស្រាលើកជូនទៅលីប៉ោ ហើយប្រើកិរិយាលោលដើមភ្នែកចុងភ្នែក ទៅឲ្យលីប៉ោស្គាល់បានថាមានចិត្តស្ម័គ្រស្រឡាញ់ ។ ចំណែកខាងអង់អ៊ុនពុតធ្វើជាស្រវឹងស្រា ហើយនិយាយទៅកាន់នាងតៀវសៀនថា ឪពុកបាស់ផឹកហើយកំឡាំងសោតក៏ថមថយ

ដឹកស្រាតែបន្តិចបន្តួចស្រវឹងរលីងអស់មុខមាត់ កូនទៅគួរសមបំរើបំរាស់ជំនួសឪពុកចុះ ៗ

ពេលនោះលិប៉ោបានឃើញនាងតៀវសៀនឲ្យអង្គុយលើកៅអី ៗ នាងតៀវសៀនក្លែងធ្វើជាអៀនខ្មាសមិនព្រមអង្គុយ ទើបគំនាប់បិតាហើយលាចូលទៅក្នុងបន្ទប់វិញ ៗ អងអ៊ុនថា កូនអើយកុំអៀនខ្មាសអ្វី លិប៉ោគេមានមេត្តាករុណាដល់យើងដូចសាច់ញាតិពិតប្រាកដ ចូរកូនអង្គុយចាក់ស្រាជូនគេតាមគួរការចុះ ៗ នាងតៀវសៀនរៀបខ្លួនអង្គុយលើកៅអីប្របអងអ៊ុន ហើយចាក់ស្រាគំនាប់លិប៉ោ, កាលចាក់ស្រាជូនវេលាណាតែងបោលកន្ទុយភ្នែកទៅប៉ះនឹងភ្នែកលិប៉ោ ៗ ឯលិប៉ោបានទទួលតែងស្រាហើយ តែងក្រឡេកភ្នែកទៅជួបនឹងភ្នែកនាងតៀវសៀនជានិច្ច, ក្នុងដួងចិត្តគិតគួរប្រតិព័ទ្ធស្នេហាស្រឡាញ់នាងពន់ពេកណាស់ ៗ អងអ៊ុនឃើញកិរិយាលិប៉ោមានចិត្តស្និទ្ធស្រឡាញ់កូនខ្លួនដូច្នោះ ក៏មានសេចក្ដីសោមនស្សជាពន្ទឹកហើយថា ខ្ញុំសព្វថ្ងៃជាមន្ត្រីមានយសស័ក្តិធំក្នុងរាជការក៏ពិត តែថាខ្លួនក៏កាន់តែជរាទុព្វលភាពណាស់ហើយ ទុបមាដូចជាដើមឈើដែលដុះក្បែរមាត់ច្រាំង ខ្ញុំនឹងលើកបុត្រីនេះជូនជាភរិយាតូចរបស់អ្នកដើម្បីប្រយោជន៍នឹងបានទុកអ្នកធ្វើរូបកាយជាទីពឹងតទៅ; ដែលខ្ញុំថាយ៉ាងនេះតើអ្នកយល់ឃើញដូចម្ដេច បើជាសេចក្ដីមិនសមគួរ កុំអ្នកប្រកាន់ទោសពៃរ៍អ្វីឡើយ ៗ លិប៉ោបានស្ដាប់ហើយក្រោកលុតជង្គង់គំនាប់

អង់អ៊ុនហើយនិយាយថា ដែលលោកឪពុកអាណិតមេត្តាខ្ញុំទាំងម៉្លេះ ព្រះគុណធំជាទីបំផុតនឹងរកប្រៀបផ្ទឹមពុំបាន ទោះបីដូចម្តេចខ្ញុំបាទនឹងធ្វើសេចក្តីតបស្នងសងគុណលោកឪពុកតទៅ ។ អង់អ៊ុនតបថា កូននេះខ្ញុំលើកជូនជាសិទ្ធដល់អ្នកហើយ ប៉ុន្តែសុំឲ្យខ្ញុំបង្អង់រើសរកឫក្សពារពេលាថ្ងៃណាដែលល្អនឹងបញ្ជូនបុត្រនេះទៅដល់ទីលំនៅអ្នកតែម្តង ។ លីប៉ោទទួលថា “ការនេះតាមតែលោកឪពុកគិតគួរចុះ” ថាហើយក៏ក្រោកឡើងប្រង់នឹងលាអង់អ៊ុន ។ អង់អ៊ុនចាប់ដៃឃាត់ថា កុំអាលសិន ដ្បិតចិត្តខ្ញុំចង់អញ្ជើញអ្នកឲ្យនៅសម្រាន្តនិយាយលេងបន្តិច តែក្រែងមហាឧបរាជត្រូវការរកអ្នក ។ លីប៉ោតបថា “លោកឪពុកមានប្រសាសន៍នោះខ្ញុំបាទអរគុណណាស់ តែថាថ្ងៃនេះខ្ញុំបាទមានកិច្ចធុរៈ ចាំដល់ថ្ងៃក្រោយសិមមកនៅទទួលទានដំណេកលេងឲ្យយូរ” ថាហើយក៏លាអង់អ៊ុនចេញទៅ ។

លុះពេលព្រឹកថ្ងៃក្រោយ អង់អ៊ុនចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ មិនបានឃើញលីប៉ោចូលទៅគាល់ជាមួយនឹងតាំងតុៈឆង ។ អង់អ៊ុនលុតជង្គង់គំនាប់តាំងតុៈហើយដំរាបថា សព្វថ្ងៃនេះខ្ញុំបាទបានសេចក្តីសុខប្រាសចាកទុក្ខភ័យអន្តរាយទាំងឡាយទាំងពួង ព្រោះព្រះតេជព្រះគុណមហាឧបរាជឃុំគ្រងរក្សាខ្ញុំបាទ នឹងរករបស់អ្វីថ្លៃថ្លាជាទីតបស្នងសងគុណគ្មាន វេលាព្រឹកថ្ងៃនេះខ្ញុំបាទសូមអញ្ជើញលោកទៅពិសា

ក្រយានៅផ្ទះខ្ញុំបាទជាសប្បាយមួង; ដែលខ្ញុំបាទជំរាបនេះ ទោះបីខុសត្រូវប្រការម្តេច សូមលោកមានសេចក្តីអនុញ្ញាតទោស ។ តាំងតុះបានស្តាប់មានសេចក្តីសោមនស្សត្រេកអរទទួលថា ដែលលោករាប់អានខ្ញុំចង់ឲ្យខ្ញុំទៅទទួលទានអាហារឯផ្ទះលោកនោះ ខ្ញុំអរណាស់ ចាំដល់ពេលថ្ងៃត្រង់ខ្ញុំនឹងទៅ ។ អង់អ៊ុនបានឮដូច្នោះហើយ ក៏លាតាំងតុះទៅរៀបចំទីលំនៅនឹងភោជនាហារបំរុងទុកជាស្រេច ។

លុះដល់ពេលថ្ងៃត្រង់តាំងតុះចេញចាកទីគាល់ ក៏ឡើងរថមានទាហានហែហមអមជាក្បួនតម្រង់ទៅផ្ទះអង់អ៊ុន ។ ចេញទៅទទួលគំនាប់ដល់ក្រៅផ្ទះ ហើយអញ្ជើញតាំងតុះឲ្យឡើងទៅកាន់ទីកន្លែងដែលរៀបក្រយាហារ ។ អង់អ៊ុនលុតជង្គង់ចាក់ស្រាគំនាប់តាំងតុះ ។ ទទួលហើយហាមថា លោកកុំលុតជង្គង់គំនាប់ខ្ញុំដូច្នោះ ចូរអង្គុយតាមទីសមគួរចុះ ។ អង់អ៊ុនធ្វើជានុនបន្ទន់ខ្លួន ហើយនិយាយលើកសរសើរតាំងតុះជាច្រើនប្រការ ។ តាំងតុះបានឮហើយលើកស្រាផឹកញញឹមញញែមក្អកក្រហែមទំនងជាពេះពាយសប្បាយចិត្តណាស់ ។ ចាប់បរិភោគអាហារជាមួយនឹងអង់អ៊ុនទាល់តែថ្ងៃរសៀល ។ រួចអង់អ៊ុនអញ្ជើញតាំងតុះទៅអង្គុយកន្លែងស្ងាត់ តាំងតុះអស់ចិត្តមិនមានគិតគ្រែងសង្ស័យ ។ ពេលនោះអង់អ៊ុនដេញមនុស្សប្រុសស្រីបំរើឲ្យចេញទៅក្រៅអស់ ហើយនិយាយថា កាលអាយុខ្ញុំបាទបាន ២៥ ឆ្នាំ ខ្ញុំបាទបានរៀនក្បួនហោរា មើលផ្កាយរក្សា

ស្រុកសម្រាប់ព្រះមហាក្សត្រនឹងផ្កាយតាំងពួង តទៅនេះខ្ញុំបានឃើញផ្កាយសម្រាប់ព្រះមហាក្សត្រនោះសៅហ្មង ឃើញផ្កាយមហាឧបរាជមានរស្មីដ៏រុងរឿង ខ្ញុំបានពីគ្រោះឃើញថា ព្រះចៅហៀនគេសព្វថ្ងៃនេះនឹងវិនាសសាបសូន្យជាដាច់ រាជសម្បត្តិនោះគង់នឹងបានដល់មហាឧបរាជជាប្រាកដ ។ តាំងគុះបានស្តាប់ដូច្នោះ មានសេចក្តីសោមនស្សត្រេកអរសួរថា ខ្លួនខ្ញុំនឹងដល់ស្វេតច្ឆ័ត្រពិតឬ? ខ្ញុំមិនទាន់ឃើញផងទេ ។ អង់អ៊ុនតបថា ទំនៀមបូរាណថាបើអ្នកឯណាគ្មានគំរេះប្រាជ្ញានឹងបុណ្យវាសនាហើយ ក៏រមែងចាញ់អ្នកមានបុណ្យមានគំរេះប្រាជ្ញា ខ្ញុំបាទឃើញដូច្នេះ ហេតុម្តេចលោកថាមិនទាន់ឃើញផងដូច្នោះ? ។

តាំងគុះតបថា បើខ្ញុំបានរាជសម្បត្តិពិតដូចពាក្យលោកថា, ខ្ញុំនឹងតាំងលោកឲ្យធ្វើជាមហាឧបរាជជំនួសខ្ញុំ ដើម្បីជាបំណាច់រង្វាន់មាត់ដែលទំនាយនោះ ។ អង់អ៊ុនធ្វើជាត្រេកអរពេញកាយសប្បាយចិត្តណាស់ ដល់វេលាព្រលប់ឲ្យអុជប្រទីបភ្លឺណាក់ក្នុងទីគ្រឹហស្ថាន ហើយឲ្យលើកក្រយាហារនឹងស្រាមកលៀងតាំងគុះម្តងទៀត ។ ពេលដែលតាំងគុះកំពុងបរិភោគអាហារនោះ អង់អ៊ុនឲ្យពួកពិណពាទ្យមហោរីប្រគំ មាននាងរបាំចេញមកច្រៀងរាំគំនាប់ ឲ្យនាងគៀវសៀនរាំបំរើតាំងគុះក្បែរៗខ្លួនៗ ឯតាំងគុះដែលប្រកបដោយចិត្តស្រឡាញ់រូបសំឡេងនៃស្រីកញ្ញា លុះក្រឡេកនេត្រាឃើញរូបនាងគៀវសៀនស្រៀវស្រស់ជាងអស់ស្រីឯទៀត

កំឡៀតគន់មើលមិនឆាក់ភ្នែក ទើបស្រែកហៅឲ្យចូលមកជិតហើយសួរអង់អ៊ុនថា នាងនេះឈ្មោះអ្វី ? ។ អង់អ៊ុនជំរាបថា ឈ្មោះនាងតៀវសៀនជាកូន ខ្ញុំសុំគេមកចិញ្ចឹមតាំងពីតូច ។ តាំងតុៈសួរថា ចេះច្រៀងដែរឬទេ ? ។ អង់អ៊ុនជំរាបថា "ចេះច្រៀងពីរោះណាស់" ថាហើយបង្គាប់ឲ្យនាងតៀវសៀនស្រែកច្រៀងទទួលតាមទំនុកភ្លេង ។

នាងតៀវសៀនស្រែកច្រៀងរាយទំនុកថា "ស្រីរូបល្អស្រស់ច្រៀងសំឡេងពីរោះ បបូរមាត់មានសម្បុរក្រហមដូចផ្លែទទ្លាប់ ធ្មេញសម្រស់ឲ្យស្រស់ឡើង ទឹងពាក់កង់យ៉ក ២ ទោះបីមិនមានក្បាច់ជារូបអ្វី មើលទៅកង់ហើយទឹងសាប់ស៊ុគ្នា ឈ្នុតាគ្រាប់ម្រេចតូចពិត កាលបើលិឈទៅដល់អណ្តាតហើយតែងមានជាតិហ៊ារក្តៅ" ។

តាំងតុៈកាលបានស្តាប់នាងតៀវសៀន ច្រៀងរៀបរាប់ទំនុកដូច្នោះ កំមានសេចក្តីសំគាល់ថាជាចម្រៀងពីរោះចាប់ចិត្ត ព្រោះមិនបានសង្កេតក្នុងកលឧបាយនៃស្ត្រី ។ អង់អ៊ុនបង្គាប់ឲ្យនាងតៀវសៀនចាក់ស្រាជូនតាំងតុៈៗទទួលហើយសួរថា នាងឯងអាយុប៉ុន្មានហើយ? ។ នាងឆ្លើយជំរាបថា ខ្ញុំម្ចាស់មានអាយុ ១៦ ឆ្នាំហើយ ។ តាំងតុៈឃើញរូបភាពស្អាតល្អ ទាំងច្រៀងក៏ពីរោះទៀត ក៏ចាប់ចិត្តក្នុងកើតប្រតិព័ទ្ធស្រឡាញ់ពេញហឫទ័យ ទើបនិយាយថា នាងឯងរូបស្អាតល្អដូចស្រីទេពអប្សរកញ្ញាទឹងរកស្រីណាប្រៀបផ្ទឹមពុំបាន ។

(មានត)

ព្រះរាជពង្សាវតារប្រទេសកម្ពុជា

ភាគទី ២

## សម័យឧដុង្គ

# អ្នកឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

ទើបត្រាស់ឲ្យភ្នាក់ងារយកគម្ពីរព្រះត្រៃបិដក និងព្រះកែវមរកតប្រតិស្ឋានទុកក្នុងក្រុងយសោធរបុរៈ[១] វេលានោះ ព្រះបាទឧទយាទិត្យវរ្ម័នទ្រង់ប្រារព្ធថា នឹងឲ្យភ្នាក់ងារចារព្រះត្រៃបិដកនោះផ្ទេរជាក់មកជាអក្សរខ្មែរទុកជាសម្បត្តិរបស់ខ្មែរ តែចារបានត្រឹមណា ចប់ឬមិនចប់ មិនអាចដឹងបានជាជាក់លាក់ ។

ចំណែកឯព្រះបាទអនុរុទ្ធ កាលស្តេចដល់ព្រះនគរហើយ មិនឃើញសំពៅព្រះត្រៃបិដកទៅដល់, ទ្រង់រង់ចាំមើលជាយូរថ្ងៃតមក

---

១ តាមពាក្យចចាមអារ៉ាមថា គម្ពីរព្រះត្រៃបិដកនិងព្រះកែវមរកត បានចូលមកដល់ប្រទេសកម្ពុជាក្នុងរជ្ជកាលព្រះបាទធនញ្ជ័យគោរព្យរាជ - ព្រះមហាក្សត្រិយ៍អង្គនេះ ត្រាស់ឲ្យយកព្រះត្រៃបិដកទៅដំកល់ទុកនៅប្រាសាទនគរវត្ត ហើយទ្រង់វេរប្រាសាទនេះថ្វាយជាវត្ត ទើបគេហៅថាប្រាសាទនគរវត្ត, ត្រាស់ឲ្យសាងប្រាសាទ ១ នៅមុខព្រះបរមរាជវាំង ហើយឲ្យយកព្រះកែវមរកតទៅប្រតិស្ឋានទុកនៅទីនោះ ។ ប្រាសាទនោះទើបមានឈ្មោះថា ប្រាសាទកែវ ។ តាមសេចក្តីពិសោធន៍របស់យើងឃើញថា វេលានោះប្រាសាទនគរវត្តមិនទាន់សាងនៅឡើយ ក្រោយនោះ ៣ រជ្ជកាលទើបបានសាង ។ ឯប្រាសាទកែវសាងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥ ដូចមានពោលហើយ ។

ទៀត ក៏មិនឃើញទោះដល់ ទើបត្រាស់ឲ្យភ្នាក់ងារស៊ើបសួរតាម មាត់សមុទ្រខាងត្បូង កន្លងមកជាយូរខែទើបបានដំណឹងថា សំពៅនោះ រសាត់ទៅដល់ប្រទេសកម្ពុជា ដូចពោលមកហើយ ។ លំដាប់នោះឯង ព្រះបាទអនុរុទ្ធមហារាជក៏ទ្រង់តែងសាសនទូត ឲ្យនាំរាជសារមកកាន់ក្រុង យសោធរបុរៈ សុំយកសំពៅព្រះត្រៃបិដកព្រះកែវមរកត ព្រមទាំងមនុស្ស ដែលមកក្នុងសំពៅនោះទៅវិញ[1] ។

ព្រះបាទឧទយាទិត្យវរ្ម័ន ទ្រង់ជ្រាបតាមព្រះរាជសារនោះហើយ ក៏ទ្រង់អនុញ្ញាតថ្វាយតាមសុំ វៀរតែព្រះកែវមរកតទ្រង់យកទុក ព្រោះ ទ្រង់ជ្រះថ្លានឹងព្រះកែវមរកតនោះជាយ៉ាងក្រៃពេក ទ្រង់បានតបព្រះរាជ-សារទៅព្រះបាទអនុរុទ្ធវិញតាមដំណើរ ។ ព្រះបាទអនុរុទ្ធកាលបាន ព្រះត្រៃបិដកទៅវិញ ដូចព្រះរាជបំណង ក៏ទ្រង់សោមនស្សខ្លាំងណាស់, បំពោះព្រះកែវមរកត ទ្រង់ពេញព្រះរាជហឫទ័យនឹងថ្វាយព្រះបាទឧទយា-ទិត្យវរ្ម័នជាកិច្ចបដិការៈ ។ ក្រោយនោះមក ៣ ឆ្នាំ (ព.ស. ១៥៩៥) ព្រះបាទអនុរុទ្ធក៏សោយទិវង្គតក្នុងវ័យមិនទាន់ទ្រង់ជរាណាស់ទេ ។

ព្រះកែវមរកត ជាវត្ថុសក្តិសិទ្ធិ ជាវត្ថុអស្ចារ្យក្នុងលោក ព្រះអង្គ អណ្តែតពីលង្កាមកស្ថិតនៅក្នុងប្រទេសកម្ពុជាអស់វេលាជាយូរឆ្នាំ ទើប

---

• ព្រះបាទអនុរុទ្ធមិនមែនមានឫទ្ធិ ដល់ទៅគង់សេះហោះមកក្រុងយសោធរបុរៈ មិនមែនមានឫទ្ធិដល់ទៅបន្ទោបស្បាតៈធ្នុះដែកថ្មឬអ្វី ៗ ដូចមានសរសេរក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជានោះទេ ។

បានទៅស្ថិតនៅក្នុងប្រទេសថៃ ដូចជានឹងមានក្នុងសេចក្តីកត់ហេតុទៅខាងក្រោយជាថ្មីទៀត ។

ព្រះមហាឧបរាជអ្នកគ្រប់គ្រងរដ្ឋទ្វារាវតី ក្នុងរដ្ឋកាលនេះ ប្រាកដព្រះនាមថា "ព្រះអាទិត្យវង្ស" ប្រហែលជាមានព្រះនាមដើម "ព្រះនារាយណ៍" សឹងជាព្រះឧរសរបស់ព្រះចន្ទ្រជោតិ ស្តេចចេញពីក្រុងលវបុរៈ ទៅតាំងព្រះរាជធានីថ្មីនៅវត្តដើម តំបន់បឹងស្នោ (ណងស្នោ) សឹងមិនឆ្ងាយប៉ុន្មានអំពីក្រុងលវបុរៈ ហើយឲ្យឈ្មោះព្រះរាជធានីថ្មីនេះថា ស្រីអយុធ្យា ព្រោះសភាពភូមិភាគប្រហែលគ្នានឹងក្រុងអយុធ្យារបស់ព្រះរាមនៅក្នុងដែនកោសល, ឈ្មោះនេះទើបកើតមានត្រឹមរដ្ឋកាលព្រះអាទិត្យវង្សនេះឯង ។

ព្រះមហាឧបរាជអ្នកគ្រប់គ្រងរដ្ឋជលៀង ក្នុងសម័យជាមួយគ្នានេះ ព្រះនាម "ព្រះរាមរាជ" ស្តេចគង់នៅកំពែងពេជ្រឬកោសម្ពីដែលឧរសព្រះរាមរាជនេះ ព្រះនាម "មណ្ឌរាជ" បានមកកាន់កាប់ក្រុងលវបុរៈ តែមិនមែនជាឧបរាជទេ នៅក្នុងបន្ទាប់ព្រះអាទិត្យវង្ស ។

**ការកសាង:** ព្រះបាទឧទយាទិត្យវរ្ម័ន ទ្រង់បានកសាងវត្តស្ថានតាមដែលដឹងបានក្នុងវេលានេះ គឺប្រាសាទសិលាឈ្មោះថា "ហេមាទ្រិ" (ភ្នំមាស) ជាទេវស្ថាន ដែលពាក្យសាមញ្ញហៅ "បាពួន" នៅក្នុងកំពែងក្រុងយសោធរបុរៈ ពីក្នុងឆ្នាំ ព. ស. ១៥៩៣ ។

តាមសេចក្តីកត់ហេតុរបស់ជាវតាគួន (ទូតចិន) ដែលមកស្រុកខ្មែរក្នុងរវាង ព.ស. ១៨៣៨ ដល់ ១៨៤០ ថាជាប្រាសាទមាសមានលក្ខណៈល្អជាបំផុត ។ តាមដែលបានពិនិត្យមើលក្នុងវេលានេះ ឃើញមានស្នាមទឹកមាសមែន ។ ប្រាសាទសិលាដែលសាងក្នុងសម័យជាមួយគ្នានេះ គឺ ប្រាសាទមេបុណ្យខាងលិច និងប្រាសាទវត្តខារ ។

ព្រះបាទឧទយាទិត្យវរ្ម័នទី ២ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិ ដល់មកក្នុងឆ្នាំ ព.ស. ១៦០៨ ក៏សោយទិវង្គត, រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា "ឧទយវរបទ" ។ ទ្រង់គ្មានព្រះរាជឱរសទទួលគ្រងរាជ-សម្បត្តិស្នងព្រះអង្គ រាជសម្បត្តិទើបបានទៅព្រះអនុជាធិរាជហរិវរ្ម័ន ។

## ព្រះបាទហរិវរ្ម័នទី ៣

ព.ស. ១៦ ៩-១៦៣២. គ.ស. ១០៦៦-១០៨៩ ។

កាលព្រះបាទឧទយាទិត្យវរ្ម័នទី ២ សោយទិវង្គតហើយ រាជការបានអញ្ជើញព្រះអនុជាធិរាជ ព្រះនាម "ហរិវរ្ម័ន" ដែលមានវ័យប្រហែលផុតមជ្ឈិមវ័យទៅហើយឲ្យឡើងគ្រងពិភពតមក មានព្រះបរមនាមថា "ព្រះបាទហរិវរ្ម័ន" រាប់ជាទី ៣ ។ ព្រះអង្គមានព្រះអគ្គមហេសីព្រះនាម "ជយរាជចូឌាមណី" តែគ្មានព្រះរាជឱរស ព្រះរាជធីតាទេ ។

**ការផែនដី :** ព្រះបាទហរិវរ្ម័នកាលទ្រង់បានឡើងសោយរាជ្យថ្មីៗនោះ មានការណ៍ក្បត់ផែនដី ដើម្បីដណ្តើមយករាជបល្ល័ង្ក, ឯអ្នក

បន្តការណ៍ក្សត់នោះគង់ជាព្រះរាជវង្ស តែព្រះនាមដូចម្ដេច មិនប្រាកដក្នុងប្រវត្តិសាស្ត្រនេះ ៗ ព្រះបាទហរិវរ្ម័នទ្រង់ជ្រាបហើយ ក៏ត្រាស់បញ្ជាឲ្យរាជសេនាធំ១នាក់លើកទ័ពទៅកម្រាប បានស្ងប់បន្តិចទៅ ៗ

**ការព្រះសាសនា** : ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់រាប់អានទាំងសាសនាព្រាហ្មណ៍ ទាំងព្រះពុទ្ធសាសនា ទ្រង់មានរាជបុរោហិតងារជា "កម្រតេងអញគុរុស្រីទិវាករបណ្ឌិត" ជាទីប្រឹក្សាការផែនដី ទឹង ធ្វើពិធីផ្សេងៗថ្វាយ ៗ ការកសាង មិនប្រាកដថាទ្រង់បានសាងអ្វីជាសំខាន់ទុកទេ ព្រោះក្នុងរជ្ជកាលនេះ មានអសន្តិសុខរហូតដល់ផុតរជ្ជកាល ៗ

ក្នុងគ្រានោះ (មិនប្រាកដជាឆ្នាំណា) ព្រះបាទហរិវរ្ម័នបានទទួលព្រះរាជសារស្ដេចក្រុងចិន ១ ច្បាប់ថ្លែងថា វេលានេះជា. ព្រះរាជអាណាខែត្រចិន ត្រូវស្ដេចយួនព្រះនាម "លីញ៉ងតុង" លើកទ័ពទៅរាយ ៗ សេចក្ដីតមក ស្ដេចក្រុងចិនទ្រង់រំលឹកអំពីរាជសម្ពន្ធមិត្រវាងខ្មែរនឹងចិនដែលមានមកក្នុងឆ្នាំ ម. ស. ៩៤៣, ព. ស. ១៤៦៤ នោះផង; ក្នុងទីបំផុត ស្ដេចក្រុងចិន សូមឲ្យព្រះមហាក្សត្រិយ៍កម្ពុជាទៅជួយកំចាត់យួន ៗ ព្រះបាទហរិវរ្ម័នទ្រង់ជ្រាបដូច្នេះហើយ ក៏ត្រាស់បង្គាប់សេនាបតីខាងទាហានឲ្យរៀបកងទ័ព ទឹងលើកទៅជួយចិន; កាលច្បាំងមានជ័យជំនះដូចបំណងស្រេចហើយ លើកទ័ពត្រឡប់មកព្រះនគរវិញ ៗ

(មានត)

# សភាតារវត្តអង្គារស

## នៅលើកំពូលភ្នំព្រះរាជទ្រព្យ ស្រុកឧដុង្គ ខេត្តកណ្ដាល


អ្នកអង្គម្ចាស់ក្សត្រី នរោត្តម-សុខាទារី

ធ្វើការនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង


(តភ្ជាប់លេខ ២ ៣ ចប់)

---

ព្រះរាជាប្រទេសខ្មែរទ្រង់ព្រួយព្រះរាជហឫទ័យណាស់ ក៏ត្រាស់បង្គាប់ឲ្យអស់នាម៉ឺនមុខមន្ត្រីខំត្រិះរិះ គិតរកប្រស្នាទាំងនេះ ។ ប៉ុន្តែក្នុងចំណោមមន្ត្រីរបស់ទ្រង់ទាំងប៉ុន្មាន ពុំមាននរណាមួយនឹងអាចដោះស្រាយប្រស្នានោះបានឡើយ ។ ទើបព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យប៉ាវគងរកអ្នកមានប្រាជ្ញាដោះស្រាយ ។ នៅសម័យនោះ មានអ្នកគង្វាលគោម្នាក់បានឃើញគេប្រឹក្សាគ្នាជុំៗ ក៏ចូលទៅឈរស្ដាប់ហើយនិយាយថា "ប្រស្នាទាំង ៣ នេះងាយដោះស្រាយសោះ: ប្រស្នាទីមួយដែលធ្វើដៃទាំងពីរវង់មូលនោះ គឺអង្រុតត្រី, ប្រស្នាទីពីរដែលក្ដាប់ដៃលើកទៅលើនោះ គឺស្នូផ្ទៃតែមួយ; ប្រស្នាទីបីដែលលាម្រាមដៃហើយបោះដៃត្រង់ទៅមុខនោះ គឺថារកបានត្រី ៥" ។ អ្នកដែលបានស្ដាប់ឮទាំងប៉ុន្មាន ក៏នាំគ្នាពិចារណាសួរបុរសនោះថានិយាយលេងឬដូចម្ដេច? ។ បុរសនោះក៏ឆ្លើយប្រាប់គេវិញថា ប្រស្នាទាំង ៣ នេះប្រាកដជាប្រែ

ដូច្នេះ ។ អ្នកស្រុកគេក៏នាំពាក្យនោះទៅជំរាបដល់មន្ត្រីដែលប៉ាវគេង, មន្ត្រីនោះក៏នាំបុរសគង្វាលគោទៅថ្វាយស្ដេច ។ ព្រះរាជាទ្រង់មានព្រះរាជឱង្ការសួរបុរសនោះ អំពីសេចក្ដីដោះស្រាយប្រស្នាទាំង ៣ នេះ; បុរសគង្វាលគោក្រាបបង្គំទូលព្រះរាជាដោយស្ងាត់ថា:

ប្រស្នាទី ១ ប្រែថា មានផែនដីមួយគឺប្រទេសខ្មែរយើង ។

ប្រស្នាទី ២ ប្រែថា មានស្ដេចមួយព្រះអង្គសោយរាជសម្បត្តិនៅលើផែនដីនោះ ។

ប្រស្នាទី ៣ ប្រែថា មានរដ្ឋមន្ត្រី ៥ នាក់ធ្វើការមើលសុខទុក្ខរាស្ត្ររងពីព្រះរាជាមក ។

លុះដល់ថ្ងៃដែលបានកំណត់ មន្ត្រីចិនក៏ចូលមកគាល់ព្រះរាជាទូលសុំសេចក្ដីដោះស្រាយប្រស្នានោះ ។ ព្រះរាជាមានព្រះរាជឱង្ការត្រាស់ហៅអ្នកគង្វាលគោឲ្យមកដោះស្រាយប្រស្នា ។ នៅវេលានោះ អ្នកគង្វាលគោក្រាបថ្វាយបង្គំព្រះរាជារួចហើយក៏ដោះស្រាយប្រស្នាទាំង ៣ នោះ បំពោះមុខអស់ពួកមន្ត្រីខ្មែរ - ចិនថា:

ប្រស្នាទី ១ គឺ បក្រពាឡមួយគឺបក្រពាឡដែលយើងនៅសព្វថ្ងៃ ។

ប្រស្នាទី ២ " មានភ្នំព្រះសុមេរុមួយដ៏ធំក្រៃលែង ។

ប្រស្នាទី ៣ " មានព្រះ ៥ អង្គត្រាស់រួចមកហើយ ។

លុះចប់ហើយ, មន្ត្រីចិនក៏ទទួលយល់ព្រមថា សេចក្ដីដោះ

ក្រោយនៃប្រស្នាទាំង ៣ នេះត្រូវហើយ រូបទើបក្រាបបង្គំលាព្រះរាជាប្រទេសខ្មែរយើងទៅទូលស្តេចខ្លួនវិញ ។ ព្រះរាជាក្រុងចិនក៏សុំចងមិត្តមេត្រីនឹងប្រទេសកម្ពុជាតាំងពីសម័យនោះដរាបមក ពុំហ៊ានរករឿងហេតុអ្វីទៀតឡើយ ។ ឯចំណែកបុរសគង្វាលគោនោះសោត ព្រះរាជាប្រទេសយើងទ្រង់ប្រោសព្រះរាជទានសម្បត្តិទ្រព្យជាច្រើន ហើយតាំងគោរម្យងារជា "ធនញ្ជ័យគោរព្យរាជ្យ" ជាងារនៅក្នុងសម័យនោះ ហើយដែលយើងសព្វថ្ងៃហៅថា "នាយករដ្ឋមន្ត្រី" ។

តមកជាយូរអង្វែង ព្រះវិហារអដ្ឋារសក៏បាក់បែកខ្ទេចខ្ទីខ្ទេចខាតអស់ នៅសល់តែសីមានឹងព្រះពុទ្ធរូប, ប្រទេសកម្ពុជាក៏ចេះតែអាប់ទុនបន្តិចម្តងៗ ដរាបមក ។ លុះនៅក្នុងសម័យលង្វែក ព្រះច័ន្ទរាជាដែលជាស្តេចទ្រង់ធម៌ ទ្រង់ត្រាស់បង្គាប់ឲ្យកសាងព្រះវិហារនោះជាថ្មី, ចំណែកព្រះពុទ្ធរូបនៅនឹងដដែលពុំមានកែប្រែឡើយ គ្រាន់តែជួសជុលបន្តិចបន្តួចប៉ុណ្ណោះ ។

## រឿងព្រះវិហារអដ្ឋារសនេះចប់តែប៉ុណ្ណោះ

ចំណែកទម្លាប់ទំនៀមខ្មែរយើង គេជ្រើសរកទីណាដែលទួលខ្ពស់មិនលិចទឹកសម្រាប់ធ្វើព្រះវិហារ ធ្វើវត្ត, គេពុំសូវកសាងវត្តនៅទីទំនាបឡើយ ។ នៅទីភូមិនីមួយៗ គេតែងតែសាងវត្តនៅពីមុខភូមិដរាប ភូមិអ្នកស្រុកត្រូវនៅពីក្រោយវត្ត ។ វត្តអារាមដែលជាទីលំនៅរបស់ពួក

បព្វជិតជាអ្នកប្រព្រឹត្តធម៌ គេច្រើនតែធ្វើឲ្យឆ្ងាយពីទីភូមិដែលមានមនុស្សកុះករ ចម្ងាយប្រមាណ ៥០០ ធ្នូ ក៏មួយធ្នូប្រវែងប្រហែលជា ២ ម៉ែត្រ. ដូច្នេះបើគិតជាម៉ែត្រវិញ វត្តត្រូវនៅឆ្ងាយពីភូមិចំនួន ១ គីឡូ ។ គេធ្វើរបៀបនេះដោយយល់ឃើញថា ពួកបព្វជិតជាអ្នកត្រូវសង្រួមកាយ-វាចា-ចិត្ត កាន់នូវសេចក្តីស្ងប់ស្ងាត់ ដូច្នេះត្រូវនៅឲ្យឆ្ងាយពីទីដែលមានមនុស្សកុះករ ដែលជាទីនាំឲ្យរំខានដល់អ្នកបួស ។ ម្យ៉ាងទៀតប្រហែលជាគេនិយមធ្វើតាមរឿងមួយ ដែលមានតាំងពីកាលព្រះពុទ្ធអង្គ គង់ព្រះធរមាននៅឡើយ គឺរឿងវត្ត "ជេតវ័ន" ដែលអនាថបិណ្ឌិកមហាសេដ្ឋីបានទិញដីភូមិនៅឆ្ងាយពីក្រុង អំពីព្រះអង្គម្ចាស់ជេត ហើយកសាងព្រះវិហារ ដាក់នាមអ្នកម្ចាស់ភូមិជានាមវត្តជាប់រហូតមកដល់សព្វថ្ងៃនេះ ។ គេសាងព្រះវិហារមិនឲ្យឆ្ងាយពីភូមិ-ពីក្រុងពេក ដើម្បីជាការងាយដល់ព្រះសង្ឃនិមន្តបិណ្ឌបាត និងដល់គ្រហស្ថធ្វើបុណ្យផង ។

លុះគេរកទីកន្លែងបានកាលណាហើយ គេក៏ចាប់ធ្វើពិធីកសាងវត្ត ។ ដំបូងគេសូត្រស្តីប្រកាសប្រាប់អ្នកទាំងឡាយឲ្យដឹងថាទីនេះៗ មានទំហំប៉ុន្មានៗ, បណ្តោយ ទទឹងប៉ុន្មានៗ នេះសូមឲ្យសំគាល់ថាជាទីវត្តអារាមចាប់តាំងពីថ្ងៃដែលបានប្រកាសនោះតទៅ ។ ឯបុក្សពារពេលាខែថ្ងៃដែលគេបានចាប់ផ្តើមសាងវត្តនោះ ជួនកាលគេយកឆ្នាំ-ខែ-ថ្ងៃកំណើតបព្វជិត១អង្គ ដែលគេប្រុងនិមន្តឲ្យមកធ្វើជាចៅអធិការវត្តនោះ, ជួនកាលគេយកខែ-ឆ្នាំ-ថ្ងៃកំណើតរបស់អ្នកសាងវត្ត មកគន់គូរមើល ។

សេនាសនៈ ដែលគេត្រូវចាប់ផ្ដើមមុនគេក្នុងវេលាសាងវត្តដំបូងគឺព្រះវិហារ តមកក្ដិលោកចៅអធិការ ។ ឯកុដិលោកចៅអធិការនេះ គេច្រើនធ្វើនៅចំហៀងឈៀងពីក្រោយព្រះវិហារបន្តិច ឬនៅចំពីក្រោយស្ពោះ គេពុំដែលហ៊ានធ្វើងខ្ទឹម ឬ ពីមុខព្រះវិហារទេ ដោយគេខ្លាចចាញ់ព្រះបារមីព្រះពុទ្ធអង្គ, ក្រោយមកគេចាប់សង់ពេងឆាន់ រួចទើបសង់បន្ទុំដាទីបំផុត ។

ក្រោយដែលគេបានសាងសេនាសនៈសំខាន់ៗ ដូចបានពោលខាងលើនេះ; គេនិមន្តព្រះសង្ឃយ៉ាងតិចត្រឹម ៥ អង្គ ។ ហេតុដែលបានជាកំណត់ចំនួនយ៉ាងនេះ ដ្បិតចំនួនបព្វជិតដែលតិចជាង ៤ អង្គនោះ គេមិនអាចហៅថាព្រះសង្ឃបានឡើយ ព្រោះពុំអាចនឹងធ្វើសង្ឃកម្មតាមច្បាប់ព្រះពុទ្ធសាសនាបានទេ ដូច្នេះវត្តក៏មិនកើតឡើងហៅថាវត្តបានដែរ ។

លុះគេសាងវត្តរួចស្រេចកាលណាហើយ គេធ្វើពិធីបញ្ចុះសីមានឹងធ្ងន់ ។ ឯសីមានោះមានពីរយ៉ាងគឺៈ មួយយ៉ាងហៅថា "សីមាទឹក" មួយយ៉ាងទៀតហៅថា "សីមាគោក" ។

ក) ឯសីមាទឹកនោះគឺ គេជីកអូរប្រឡាយទឹកនៅជុំវិញទីដីដែលគេសន្មតទុកជាព្រំប្រទល់វត្ត ជាទីកន្លែងដែលគេត្រូវគោរព, នៅក្នុងអូរនោះគេជីករណ្ដៅ ៨ នៅជុំវិញវត្តនោះទៅគ្រប់ទិសទាំង ៨, នៅក្នុងព្រះវិហារ

គេជីករណ្ដៅមួយដែរ នៅចំពីមុខព្រះពុទ្ធរូបជិតបល្ល័ង្កព្រះ, ហើយគេបង្ព្យួរថ្មមួយដុំ (ទម្ងន់យ៉ាងតិចត្រឹម ៦០ នាឡិ) នៅលើមាត់រណ្ដៅទាំង ៩ នោះ ។ គេនិមន្តព្រះសង្ឃទៅសូត្រធម៌នៅត្រង់រណ្ដៅទាំងនោះហើយ លុះដល់ពេលវេលាដែលត្រូវការ គេធ្វើកិច្ចសញ្ញាអ្វីមួយឲ្យបានដឹង (ដូចជាវាយគង ជាដើម) ដើម្បីឲ្យគេកាត់ខ្សែទម្លាក់ដុំថ្មដែលគេសន្មតហៅថាសីមានោះទៅក្នុងរណ្ដៅបានព្រមព្រៀងគ្នា ។

ខ) សីមាគោក គឺសីមាដែលគេបញ្ចុះនៅលើគោក ពុំមានជីករណ្ដៅអូរឲ្យដក់ទឹកបានឡើយ ។ សីមាទាំងនេះ ខ្លះគេបញ្ចុះនៅឯវេបង្វត្តក៏មាន ខ្លះគេបញ្ចុះនៅលើខឿនព្រះវិហារក៏មាន ខ្លះទៀតបញ្ចុះនៅក្នុងព្រះវិហារក៏មានដែរ តាមតែចិត្តអ្នកសាងវត្តចង់ធ្វើនៅទីណាក៏បាន ឲ្យតែទីនោះចុះល្មមព្រះភិក្ខុសង្ឃ ២១ រូបអង្គុយដំកងមូល ឃ្លាតឆ្ងាយអំពីគ្នាមួយត្រដាងដៃ ។ ឯពិធីបញ្ចុះសីមានោះមានរបៀបដូចជាពិធីបញ្ចុះសីមាទឹកដែរ ។ សីមាដែលនៅចំមុខព្រះក់ក្រ្តព្រះជិតបល្ល័ង្កនោះហៅថា "សីមាកិល" ។

នៅទីបំផុត, គេរៀបចំធ្វើបុណ្យឆ្លងព្រះវិហារ ។ ឯបុណ្យនោះកាលដំបូងគេនិមន្តព្រះភិក្ខុសង្ឃជាច្រើនរូបមកសូត្រមន្តចំរើនព្រះបរិត្ត ។ នៅលើគោកបុត្តមួយៈគេមានរៀបផ្ទៃឈើទីងទំចំណី ៤ ចានតូចៗ ដាក់ជា ៤ ជ្រុង ហើយមានធ្វើជមតូចៗ ៤ ដែលមានដោតស្លឹកម្លូស្លឹកខ្នុរជា

៣ ជ្រុងដាក់នៅក្នុងគោកនោះដែរ, នៅចំកណ្ដាលគេដាក់ទឹកមួយផ្តិល ដែលគេចងមែកឈើព្រមទាំងស្លឹកបណ្ដោតនៅក្នុងនោះ ។ លុះលោកសូត្រធម៌ចប់រួចស្រេចកាលណា គេយកទឹកនោះទៅប្រស់ពេញតែទីកន្លែងក្នុងព្រះវិហារ ។ នៅវេលាព្រឹកគេនិមន្តព្រះសង្ឃមកសូត្រធម៌ហើយប្រគេនចង្ហាន់ឆាន់ ។ លុះដល់ពេលរសៀលគេធ្វើមហាទាន គឺទេសនា. សង្គាយនាត្រៃ ៣ ជាកិច្ចបង្ហើយបុណ្យ ។

ពិធីឆ្លងចប់តែប៉ុណ្ណោះ

នៅព្រះវិហារនីមួយ ៗ គេបានសង្កេតឃើញមានធ្វើរូបគ្រុឌទ្រយ៉ាបដំបូលព្រះវិហារ រូបនាគលូនវែងលៃនៅលើដំបូល, រូបយក្ខគន្ធព្វកាន់ដំបងឈរចាំនៅមាត់ទ្វារ, រាជហង្សទំនៅកំពូលក្លោងទ្វារ - ។ល។ ឯរូបសត្វទាំងអស់នេះ ពុំមានរឿងរ៉ាវអ្វីទាក់ទងដល់ការកសាងវត្តទេ ប៉ុន្តែគេតែងនិយមយកទៅតាំងនៅព្រះវិហារ ដោយសត្វទាំងនោះមានរិទ្ធិល្បីល្បាញក្នុងរឿងរ៉ាវបុរាណខ្មែរយើង ទើបបានគេយកមកធ្វើជារបស់តាំងលំអនៃព្រះវិហារ ហើយដាក់តាមទីកន្លែងឲ្យសមរម្យតាមសភាពរូបរាងកាយរបស់សត្វទាំងនោះ កុំឲ្យជាទីទើសទែងជាទីរំខានដល់ទីកន្លែងនឹងទស្សនាផង ។

ចប់

## ប្រវត្តិរបស់អេសុប

# លោក ផេង-ជើវ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ភ្នំពេញ

## ប្រែពីបារាំងមកជាខ្មែរ

(តទៅ)

---

សន្ទុះមានប្រពន្ធមួយជាស្រីចិត្តមួម្មួអាក្រក់ពេកណាស់ គ្មាននរណាចេះធ្វើឲ្យត្រូវចិត្តឡើយ ហើយជាស្រីខឹងច្រើនផង ។ បើសន្ទុះនាំអេសុបយកទៅប្រគល់ឲ្យនោះមុខជាខឹង ដោយគិតស្មានថាគេយកមនុស្សដូច្នេះទៅចំអកឲ្យ ។ សន្ទុះចង់សើចលេងនឹងប្រពន្ធរបស់ខ្លួនក៏ទៅនិយាយប្រាប់មុនថា : អញទិញបានមនុស្សម្នាក់ រូបរាងល្អចំឡែក រកប្រុសណាល្អដូចគ្មាន ។ ពួកបាវស្រីៗ របស់ប្រពន្ធសន្ទុះគិតចង់ដណ្តើមគ្នាឲ្យនៅបំរើជាមួយ ។ តែលុះអេសុបមកដល់កាលណា ខ្លះយកដៃខ្ទប់មុខ ខ្លះរត់ចេញ ខ្លះស្រែកថា យីអីចេះ ! ។ ចំណែកនាងប្រពន្ធស្រែកថា: ចង់ដេញអញឲ្យចេញពីផ្ទះឬ បានជាយកមនុស្សមុខខ្មោចហ្នឹងមក ? ។ ព្រោះលោកសន្ទុះឈប់ទៅមករកនាងនេះជាយូរណាស់ផង ។ ការប្រឈ្លោះគ្នាមួយម៉ាត់ជាពីរម៉ាត់ រហូតដល់នាងប្រពន្ធសុំឲ្យចែកទ្រព្យសម្បត្តិគ្នា ដើម្បីទៅផ្ទះរបស់ឪពុកម្តាយខ្លួន ។ ប៉ុន្តែដោយអំណាចនៃការអត់ទ្រាំរបស់លោកសន្ទុះ និងប្រាជ្ញានៃអេសុបដែលឆ្លាតក្នុងការនិយាយ, ស្វាមីភរិយាក៏បានស្រុះស្រួលគ្នាឡើងវិញ ។

ថ្ងៃមួយលោកសង្ឃ័ះនឹងអេសុបទៅឯសួនច្បារមួយ ដើម្បីរកទិញបន្លែ ។ នាយច្បារបេះបាចស្មៅមួយគាប់ ហើយសូមឲ្យលោកសង្ឃ័ះអធិប្បាយឲ្យស្តាប់ថា: ចុះបន្លែដែលខ្ញុំខំប្រឹងដាំហើយស្រោចទឹករាល់ថ្ងៃ ហេតុអ្វីក៏វាបេះតែមិនសូវលាស់ល្អ ចំណែកស្មៅលតាវល្លិទាំងឡាយគ្មានអ្នកណាដាំ គ្មានអ្នកណាស្រោចទឹកថែរក្សាសោះ វាក៏បេះតែលាស់ល្អអ្វីម្ល៉េះ? ។ សង្ឃ័ះទាល់ប្រាជ្ញ នៅស្ងៀម, អេសុបឃើញអាការរបស់ម្ចាស់ដូច្នោះសើចញឹម ៗ ចាប់ដៃម្ចាស់ទាញមកកៀនរបង ហើយខ្សឹបប្រាប់ថា: សូមលោកឆ្លើយតបទៅនាយច្បារថា: បញ្ហាបែបហ្នឹងមិនគួរដល់ខ្លួនខ្ញុំទេ ឲ្យតែក្មេងរបស់ខ្ញុំឆ្លើយដូសក៏បានដែរ ។ សង្ឃ័ះបានទៅនិយាយប្រាប់នាយសួនច្បារតាមពាក្យអេសុប ហើយដើរលេងធ្វើព្រងើយទៅក្បែររបង ។ អេសុបអធិប្បាយប្រាប់នាយសួនច្បារជាពាក្យឧបមាឧបមេយ្យថា: ដីដូចស្រីមេម៉ាយមានកូន ហើយយកប្តីពោះម៉ាយមានកូនដែរ: នាងនេះតែងតែមានចិត្តស្នេហាចំពោះកូនដើមរបស់ខ្លួនជាងកូនរបស់ប្តី បើបានវត្ថុអ្វី ។ តែងតែប្រួចយកឲ្យកូនរបស់ខ្លួនស៊ីច្រើនជាងកូនរបស់ប្តី; ចំណែកដីក៏ដូចស្រីមេម៉ាយនេះដែរ ។ នាយច្បារដែលពេញចិត្តនឹងពាក្យឧបមានេះ ក៏ឲ្យអេសុបយកតាមចិត្តនូវបន្លែដែលមាននៅក្នុងសួន ។

មិនទាន់កន្លងយូរបានប៉ុន្មានថ្ងៃ សង្ឃ័ះនឹងភរិយាទាស់ទែងគ្នាទៀត ។ លោកនេះអញ្ជើញទៅពិសាលៀងភោជនាហារ បានយកបង្អែមយ៉ាង

ឆ្ងាញ់ទុកមួយចំណែក ហើយប្រាប់អេស៊ុបថា "ចូរឯងយកវត្ថុនេះទៅឲ្យនាងជាសំឡាញ់របស់អញ ។ អេស៊ុបមិនយកទៅឲ្យប្រពន្ធរបស់ចៅហ្វាយនាយ ត្រឡប់ជាយកទៅឲ្យមេឆ្កែបញ្ចឹមស៊ីវិញ ។ សង្ធុះដែលត្រឡប់មកវិញ សួរភរិយាថា: ម៉េចអូនឯងញុំាបង្អែមឆ្ងាញ់ឬទេ? ។ ភរិយាធ្វើក្អែកឡឹងឡង់សួរថា: បង្អែមនៅឯណា? ។ ប្ដីថា: អញឲ្យអេស៊ុបយកមកឲ្យ ។ សង្ធុះសួរអេស៊ុបថា: អញមានប្រាប់ឯងថាចូរយកបង្អែមនេះទៅឲ្យនាងជាសំឡាញ់របស់អញឬទេ? ។ អេស៊ុបឆ្លើយថា: មែន ប៉ុន្តែនាងជាសំឡាញ់របស់លោក មិនគឺប្រពន្ធរបស់លោកទេ ដែលគ្រាន់តែមានរឿងហេតុអ្វីបន្តិចបន្តួចក៏លែងលះគ្នា គឺប្រាកដជាមេឆ្កែឯណោះទេ បានហៅថាសំឡាញ់របស់លោកមែន ព្រោះទោះបីលោកវាយក៏ដោយ ជេរក៏ដោយ វាចេះតែមករកលោកវិញ មិនចេះខឹងសម្បាតបនឹងលោក ។ សំដីប៉ុណ្ណោះធ្វើឲ្យសង្ធុះរកយកទោសមិនកើត ។ ចំណែកខាងប្រពន្ធដែលខឹងពេកក៏រត់ទៅកាន់ផ្ទះរបស់ឪពុកម្ដាយ សូម្បីសំឡាញ់ឬបងប្អូនណាមកនិយាយឲ្យស្រុះស្រួលក៏មិនព្រម ។ ឃើញការណ៍ដូច្នោះ អេស៊ុបគិតធ្វើកលមួយដើម្បីនឹងឲ្យភរិយានៃចៅហ្វាយរបស់អាត្មាត្រឡប់មកផ្ទះវិញ ។ លោកយកកញ្ជើមួយទៅផ្សារ ហើយធ្វើជាទិញបន្លែនឹងអីវ៉ាន់យ៉ាងច្រើន ៗ កំពុងតែរៀបរបនឹងទិញទំនិញ លោកប្រទះនឹងបាវស្រីរបស់ប្រពន្ធនៃលោកសង្ធុះ ។ នាងនេះសួរថា: ឯងទិញអីវ៉ាន់ធ្វើអ្វីក៏ច្រើនម្ល៉េះ? ។

លោកឆ្លើយថា: អញវិញយកទៅគិតរៀបអាពាហ៍ពិពាហ៍ជូនលោកសង្ឃះទៀត ដ្បិតប្រពន្ធរបស់លោកទៅផ្ទះឪពុកម្ដាយហើយ លោកត្រូវតែរកប្រពន្ធថ្មីទៀត ។ ប្រពន្ធរបស់លោកសង្ឃះបានដំណឹងដូច្នោះ ដោយសេចក្ដីប្រណែនប្ដីប្រច័ណ្ឌត្រឡប់មកផ្ទះវិញជាប្រញាប់ ហើយឈប់ខឹងខឹងប្ដីនៃខ្លួន ។ មិនមែនជាឥតគំនុំសោះទេ ដែលអេសុបចេះតែរករឿងធានៅម្ចាស់របស់ខ្លួនឯងជានិច្ចជាកាល ហើយអម្ពាលខឹងដោះសាទោសនៃខ្លួនវិញ ដោយសារខ្លួនមានប្រាជ្ញាវាងវៃ; លោកសង្ឃះមិនមែនជាមិនខឹងឡើយ ។

ថ្ងៃមួយជាថ្ងៃបុណ្យ ចៅហ្វាយរបស់លោករៀបស៊ីលៀងហៅពួកមិត្តភក្តិជាច្រើនមកស៊ីផឹក ហើយប្រាប់លោកឲ្យទៅទិញម្ហូបអ្វីដែលល្អជាងគេយកមកធ្វើឲ្យភ្ញៀវស៊ី ។ អេសុបគិតក្នុងចិត្តថា: ម្ដងនេះអញនឹងបង្រៀនម្ចាស់អញឲ្យស្គាល់ឲ្យចេះអធិប្បាយសព្វគ្រប់ នូវដំណើរដែលអ្នកត្រូវការប្រាថ្នា កុំឲ្យតែមានការអ៊ូចេះតែចំលាក់ទៅលើតែបាវព្រាវពេក ។ អេសុបទៅផ្សារទិញសុទ្ធតែអណ្ដាតយកមកធ្វើម្ហូបឲ្យភ្ញៀវស៊ី ។ ដំបូងពួកភ្ញៀវសរសើរថាម្ហូបនេះឆ្ងាញ់មែន លុះយូរបន្តិចទៅស៊ីតែអណ្ដាតដដែលក៏ត្រឡប់ជាបាត់ឆ្ងាញ់ ។ សង្ឃះខឹងហៅអេសុបមកសួរថា: អញប្រាប់ឲ្យឯងទិញរបស់ល្អៗហេតុអ្វីក៏ឯងទិញសុទ្ធតែអណ្ដាតយកមកធ្វើឲ្យគេស៊ី ? ។ លោកឆ្លើយថា: របស់អ្វីល្អជាងអណ្ដាត! អណ្ដាតហ្នឹងហើយជាខ្សែ

សំរាប់ចងស្ពានមេត្រីភាពជាតិនានារបស់មនុស្សក្នុងលោក ជាកូនសោនៃវិជ្ជាទាំងឡាយ ជាគ្រូនៃពាក្យសត្យនិងសេចក្ដីស្រស់ស្រួលដោយសារអណ្ដាតហ្នឹងហើយ គេអាចតាំងទីក្រុងហើយរៀបចំឲ្យបានស្អាត គេរៀនចំណេះផ្សេងៗ គេនិយាយពន្យល់ គេអាចតាំងខ្លួនទៅកណ្ដាលទីប្រជុំធំៗបាន គេពោលសរសើរនូវគុណ របស់ព្រះជាម្ចាស់ដែលជាករណីយកិច្ចឯក ដែលមនុស្សត្រូវបំពេញមុនករណីយកិច្ចទាំងពួង ។ សង្ហះចង់រករឿងចាប់លោកឲ្យបាន ព្រោះខឹងនឹងសំដីរបស់លោកត្រូវពេករកធ្លើយដោះមិនរួចក៏ប្រាប់ទៀតថា: ចូរឯងទៅទិញវត្ថុអ្វីដែលអាក្រក់ជាងគេយកមកធ្វើម្ហូបទៀត ស្អែកអញហៅភ្ញៀវមកស៊ីលៀងទៀត ។

ព្រឹកឡើង អេសុបស្ងួតតែអណ្ដាតដដែល ហើយអធិប្បាយប្រាប់ថា អណ្ដាតគឺជាមេនៃជម្លោះទាំងឡាយ ជាមេចិញ្ចឹមនូវរឿងក្ដីជាប្រភពនៃការបំបែកបំបាក់គណៈនិងចំបាំង, មួយទៀតអណ្ដាតដែលគេពោលថាជាគ្រូនៃសេចក្ដីពិត ក៏អណ្ដាតនេះឯងដដែល ជាគ្រូនៃសេចក្ដីបំភាន់ ហើយបើថាឲ្យអាក្រក់ជាងនេះទៅទៀត គឺជាមេនៃពាក្យបន្ទាប់ដោយសារអណ្ដាតគេអាចបំផ្លាញទីក្រុង គេធ្វើឲ្យជឿតាមនូវវត្ថុអាក្រក់ទាំងឡាយ កាលណាគេនិយាយថា អណ្ដាតសម្រាប់ពោលសរសើរគុណរបស់ព្រះជាម្ចាស់ គឺអណ្ដាតហ្នឹងដដែល សម្រាប់ពោលត្មះតិះដៀលគុណរបស់ព្រះជាម្ចាស់ដែរ ។

## ប្រវត្តិព្រះកែវមរកត

## អ្នកឧកញ៉ា ទេពពិទូរ ក្រឹសេម គន្ធបណ្ឌិត *រៀបរៀង*

(ត ចប់)

កាលទៅដល់ហើយ ស្ដេចព្រមដោយព្រះរាជបរិពារចូលទៅគាល់ព្រះបាទលង្កិស្សរាជ ៗ ទ្រង់ធ្វើបដិសណ្ឋារៈ ដោយមេត្រីចិត្តយ៉ាងខ្ពស់ រួចហើយស្ដេចទៅគាល់ព្រះមហាសង្ឃបរិនាយក នៅមេឃគិរីមហាវិហារ ដែលជាទីសិក្សាយ៉ាងធំ ហាក់ដូចជាមហាវិទ្យាល័យបរិយត្តិធម៌ក្នុងសម័យនោះ សុំចំឡងព្រះត្រៃបិដកដ៏ជាភាសាបាលី ១ ចប់ នឹងជាភាសាលង្កា ១ ចប់ទៀត ៗ

កាលបើចំឡងចប់ហើយ ព្រះបាទអនុរុទ្ធត្រាស់សុំព្រះកែវមរកត យកទៅទុកជាទីរលឹក, ព្រះបាទលង្កិស្សរាជក៏ព្រមថ្វាយ ៗ ព្រះបាទអនុរុទ្ធក៏ត្រាស់ឲ្យជញ្ជូនព្រះត្រៃបិដកភាសាបាលីដាក់សំពៅ ១, ឲ្យជញ្ជូនព្រះត្រៃបិដកសម្រាយនឹងព្រះកែវមរកតដាក់សំពៅ ១, ចំណែកព្រះអង្គស្ដេចទ្រង់គង់សំពៅដែលដាក់ព្រះត្រៃបិដកបាលី, សំពៅទាំងពីរក៏បើកចេញចាកកោះលង្កា សំដៅមកប្រទេសភូមា; តែកាលមកដល់កណ្ដាលសមុទ្រ, សំពៅដែលផ្ទុកព្រះត្រៃបិដកសម្រាយនឹងព្រះកែវមរកត បានត្រូវខ្យល់ព្យុះបោកបក់រសាត់មកជាប់នៅត្រើយសមុទ្រ ត្រង់ជាយខែត្របន្ទាយមាសនៃប្រទេសកម្ពុជាភាគខាងត្បូង ៗ

ក្រមការវេតេចាប់សំពៅនេះបាន  ក៏នាំយកគម្ពីរព្រះត្រៃបិដក សម្រាយនឹងព្រះកែវមរកតទៅថ្វាយព្រះមហាក្សត្រិយ៍ព្រះនាម ព្រះបាទសូរ្យវង្សទី ១ នៅក្រុងស្រីយសោធរបុរៈ,  ទ្រង់សោមនស្សណាស់ឲ្យទទួលដំកល់ទុកក្នុងព្រះវិហារ ១ ខាងក្នុងព្រះបរមរាជវាំង ។

ក្រោយនោះ  ពត៌មាននេះបានជ្រាបទៅដល់ព្រះបាទអនុរុទ្ធ ក៏ត្រាស់ប្រើព្រះរាជបំរើឲ្យនាំព្រះរាជសារមកសូមយករបស់អំបាលនោះទៅវិញ ។ ព្រះបាទសូរ្យវង្សទី ១ ត្រាស់ឲ្យប្រគល់ឲ្យទៅវិញទាំងអស់ វៀរតែព្រះកែវមរកត ទ្រង់យកទុក ។  ព្រះកែវមរកតបានមកស្ថិតនៅក្នុងប្រទេសកម្ពុជាដោយអាការយ៉ាងនេះ ។

## រយៈទី ៤

# ព្រះកែវមរកតចេញពីក្រុងស្រីយសោធរបុរៈ ទៅស្ថិតនៅក្រុងស្រីអយុធ្យាដ៏ជាបច្ចន្តរដ្ឋរបស់កម្ពុជា

ពី ព. ស. ១៦២៣ ដល់ ១៦៤០

កាល ព. ស. ១៦២៣ ក្នុងរជ្ជកាលព្រះបាទហសិវង្ស[1] ទី ៣, ក្រុងស្រីយសោធរបុរៈត្រូវទឹកលិចធំយ៉ាងខ្លាំង ទាំងត្រូវចាប់លើកទំពដើងទឹកមកវាយទៀតផង ។ ព្រះបាទហសិវង្សត្រាស់ឲ្យភ្នាក់ងាររាជពាំនព្រះរាជទ្រព្យសំខាន់ៗ នឹងព្រះកែវមរកតដាក់ទូក - សំពៅ ស្តេចព្រម

---

១ ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាហៅក្សត្រិយ៍អង្គនេះថា « សេនករាជ » ។

ដោយព្រះរាជវង្សានុវង្ស និងមន្ត្រីខ្លះទៅសំចតនៅជើងភ្នំដងរែកដែលទឹកមិនបានលិចដល់ ។

គ្រានោះ ព្រះអាទិត្យវង្សជាមហាឧបរាជខ្មែរដែលគង់នៅក្រុងស្រីអយុធ្យា ក្នុងវេលាកាលតែបានទ្រង់ជ្រាបពត៌មាននេះហើយ ក៏ស្ដេចមុខមា-យាងចុះទូកព្រះទីនាំង ព្រមដោយពួកទាហានជើងទឹកនិងទូកធំៗឯទៀតជាច្រើន មកទទួលព្រះបាទហស៌វរ្ម័នយកទៅឯក្រុងស្រីអយុធ្យា ឲ្យផុតអំពីសេចក្ដីអន្តរាយ ។

ក្រោយដែលព្រះបាទហស៌វរ្ម័នស្ដេចយាងផុតទៅហើយ ទ័ពចាម្ប៉ាក៏ចូលលុកក្រុងស្រីយសោធរបុរៈ ជញ្ជូនយកទ្រព្យសម្បត្តិនិងដុតផ្ទះសំបែងអស់ជាច្រើន ។ កាលចាម្ប៉ាលើកទ័ពត្រឡប់ទៅវិញហើយ មានព្រះរាជវង្ស ១ ដែលមិនស្គាល់ព្រះនាមបានរួបរួមសេនារេហ៍ពលតាំងខ្លួនជាព្រះរាជានៅជើងភ្នំដងរែក ។ គ្រានោះ មានព្រះរាជវង្ស ១ អង្គទៀតព្រះនាមជយវរ្ម័ន គឺព្រះបាទជយវរ្ម័នទី ៦ ទ្រង់រួបរួមកងទ័ពបានជាច្រើនហើយ ក៏លើកចូលទៅគ្រងក្រុងស្រីយសោធរបុរៈ... ។

ចំណែកព្រះបាទហស៌វរ្ម័នទី ៣ កាលទ្រង់ជ្រាបថា ព្រះបាទជយៈវរ្ម័នឡើងគ្រងរាជបល្ល័ង្កនៅក្រុងស្រីយសោធរបុរៈហើយ ក៏អស់ផ្លូវដែលនឹងគិតត្រឡប់មកព្រះនគរវិញ ទ្រង់តាំងព្រះរាជហឫទ័យថានឹងគង់នៅឯនគរស្រីអយុធ្យាតទៅទៀត តែព្រះរាជបំណងនេះមិនបានសម្រេចបទ

ដោយអាយុខ័យមកដល់ ព្រះអង្គក៏សោយទិវង្គតក្នុងឆ្នាំនោះទៅ ។ ព្រះនាងជយកជច្ចឡាមណីជាអគ្គមហេសី ទ្រង់គង់នៅនគរស្រីអយុធ្យា រហូតដល់រដូវប្រាំង ទើបទ្រង់លាព្រះអាទិត្យវង្សត្រឡប់មកព្រះនគរវិញ, ព្រះអាទិត្យវង្ស មុននឹងរៀបក្បួនជូនព្រះរាជដំណើរ បានក្រាបទូលសូមព្រះកែវមរកតទុក, ព្រះនាងក៏ព្រមព្រះរាជទានតាមសុំ ព្រោះព្រះអាទិត្យ-វង្ស បានធ្វើឧបការៈចំពោះព្រះនាងជាច្រើន ដូចពោលហើយ ។

ព្រះកែវមរកតបានចេញចាកក្រុងស្រីយសោធរបុរៈ ទៅស្ថិតនៅនគរស្រីអយុធ្យាដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា ដោយអាការយ៉ាងនេះ ។

## រយៈ ទី ៤

## ព្រះកែវមរកតចេញចាកនគរស្រីអយុធ្យា ទៅស្ថិតនៅនគរកំពែងពេជ្រឬហៅនគរកោសម្ពី

ពី ព. ស. ១៦០០ ដល់ ១៩៦០

ក្នុងរវាងប្រមាណ ព. ស. ១៦០០ ឆ្នាំយ មានព្រះមហាឧបរាជខ្មែរ ១ អង្គព្រះនាម "រាមរាជ" នៅនគរកំពែងពេជ្រក្នុងរដ្ឋជាលៀងដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា ជាមហាមិត្រជិតដិតនឹងព្រះអាទិត្យវង្ស បានមកសុំយកព្រះកែវមរកតអំពីព្រះអាទិត្យវង្ស ទៅទុកបូជានៅនគរកំពែងពេជ្រ ។ កាលយកទៅមិនយូរប៉ុន្មាន ព្រះមណ្ឌរាជជាឱរសព្រះរាមរាជនៅលវបុរៈ (លពបុរី) ក្នុងឋានៈជាចៅហ្វាយស្រុក បានទៅ

សុំយកព្រះកែវមរកតអំពីព្រះរាមរាជជាព្រះរាជបិតា ទៅទុកបូជានៅលវបុរៈ ។ តែយកទៅមិនយូរប៉ុន្មាន ក៏នាំគ្នាយកទៅថ្វាយព្រះរាជបិតាវិញ, ព្រះរាមរាជទ្រង់ប្រតិស្ឋានទុកនៅក្នុងព្រះវិហារធំ ១ នៅក្រុងកំពែងពេជ្រ នៅរហូតដល់ឆ្នាំ ព.ស. ១៦៦០ ។

ព្រះកែវមរកតបានទៅប្រតិស្ឋាននៅនគរកំពែងពេជ្រដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា ដោយអាការយ៉ាងនេះ ។

សរុបវេលាដែលព្រះកែវមរកតមកស្ថិតនៅក្នុងកម្ពុជរដ្ឋ

| | | |
|---|---|---|
| នៅក្រុងស្រីយសោធរបុរៈ | ៦៣ | ឆ្នាំ |
| នៅនគរស្រីអយុធ្យា | ១៧ | ឆ្នាំ |
| នៅនគរកំពែងពេជ្រ | ២០ | ឆ្នាំ |
| រួមជា | ១០០ | ឆ្នាំគត់ |

រយៈទី ៦

## ព្រះកែវមរកតចេញចាកនគរកំពែងពេជ្រ ទៅស្ថិតនៅយោនកនាគនគរ (ជៀងសែន) រួមទាំងនគរជៀងរ៉ាយ និងនគរទេលាង្គ

តាំងពី ព.ស. ១៦៦០ ប្រមាណដល់ ២០២០

ចាប់តាំងពីឆ្នាំ ព.ស. ១៦៦០ ព្រះកែវមរកតរបស់យើងបានធ្លាក់ទៅនៅក្នុងកណ្តាប់ដៃជាតិដទៃ ។ ដោយក្នុងរវាង ព.ស. ១៦៥១

ដល់ ១៦៥៦ ជារជ្ជកាលព្រះបាទនរេណ្ទ្រូវ័ន្ទទី ១ សោយរាជ្យនៅក្រុងស្រីសោធរបុរៈនោះ ទ្រង់ខ្សោយព្រះតេជានុភាព ជាហេតុឲ្យមានការណ៍បះបោរក្នុងព្រះនគរ មិនត្រឹមតែក្នុងព្រះនគរទេ ស្រុកចំណុះខ្លះក៏បះបោរឡើងដែរ ដើម្បីតាំងឥស្សរភាពឡើង; ដោយចំពោះជាតិថៃ (សៀម) មានបុរស ១ នាក់ឈ្មោះព្រហ្មរាជ ជាបុត្រពង្គរាជ បានលបតាំងឥស្សរភាពឡើងនៅស្រុកយោនក ជៀងសែន[1] ប្រមាណក្នុងរវាង ព.ស. ១៦៤០-១៦៥០ ។

មកក្នុងឆ្នាំ ព.ស. ១៦៥៦ ព្រះបាទស្សូរ្យវ័ន្ទទី ២ ជាវីរបុរសទ្រង់បានសោយរាជសម្បត្តិជាតំណមកអំពីព្រះបាទនរេណ្ទ្រូវ័ន្ទទី ១ ទ្រង់រវល់ក្រោមអសន្តិសុខខាងក្នុងអស់វេលា ៤-៥ ឆ្នាំ ទំរាំតែបានសាន្តត្រាណ ។ វេលានោះ (ព.ស. ១៦៦០) ព្រះព្រហ្មរាជឃើញខាងក្នុងប្រទេសវឹកវរខ្វាំងដូច្នោះ ក៏ឆក់យកឱកាសនោះរួបរួមកងទ័ពលើកមកសង្កត់សង្កិនព្រំ នៅជាយតាមព្រះរាជអាណាចក្រភាគខាងលិច រហូតមកដល់នគរកំពែងពេជ្រ ដោយរាជការខ្មែរដែលនៅប្រចាំរដ្ឋនោះមិនដឹងខ្លួន ។ ព្រះព្រហ្មរាជបានចូលទៅជួបនឹងព្រះរាមរាជ មហាឧបរាជខ្មែរនៅក្រុងកំពែងពេជ្រ, បានឃើញព្រះកែវមរកតនៅក្នុងព្រះវិហារក៏សុំយកទៅ ។ ព្រះរាមរាជទើសទាល់ ក៏គោងលើកឲ្យទៅទាំងមិនស្ម័គ្រ ។

---

១ ចូលមើលសេចក្តីពិស្តារក្នុងព្រះរាជពង្សាវតារក្នុងរជ្ជកាលព្រះបាទនរេណ្ទ្រូវ័ន្ទទី ១ ។

ព្រះព្រហ្មរាជ កាលបានព្រះកែវមរកតហើយ មានសេចក្ដីព្រួយដោយកែ្រងខ្មែរលើកទ័ពទៅដណ្ដើមយកមកវិញ ក៏គិតធ្វើឧបាយបំបាត់កស្តុតាង ដោយយកបាយអមកបូកស្រោបព្រះកែវមរកតនោះផិត ឲ្យមើលឃើញជាព្រះពុទ្ធរូបធម្មតា ហើយយកទៅលាក់ទុកយ៉ាងគត់មត់ ។

បំណែកព្រះបាទសូរ្យវង្សទី ២ កាលទ្រង់ក្រោមអសន្តិសុខទាំងក្នុងបានរាបទាបហើយ ស្ដេចៈលើកទ័ពទៅក្រោមការណ៍បះបោរនៅតាមស្រុកចំណុះទាំងប៉ុន្មានឲ្យស្ងប់រាបទាបដូចដើមវិញ; ពួកថៃ (សៀម) ដែលមានព្រះព្រហ្មរាជជាប្រមុខ ក៏ត្រឡប់មកនៅក្រោមឥទ្ធិពលរបស់ព្រះអង្គតមកទៀត ។

មានពាក្យបុច្ឆាសួរថា: កាលព្រះបាទសូរ្យវង្សទី ២ បានគ្រប់គ្រងជាតិថៃដូចដើមវិញហើយ ហេតុម្ដេចក៏មិនស្រាវជ្រាវយកព្រះកែវមរកតមកវិញ? ។ មានពាក្យដោះស្រាយថា: ១ - ព្រោះព្រះព្រហ្មរាជយកទៅធ្វើបំបាត់ដានដូចបានពោលហើយ បើទុកជាស្រាវជ្រាវរកក៏មិនងាយនឹងឃើញមកវិញ; ២ - ព្រោះព្រះបាទសូរ្យវង្សទី ២ ទ្រង់កាន់សាសនាព្រាហ្មណ៍លទ្ធិវៃស្ណវៈ រឿងព្រះកែវមរកតទ្រង់មិនបានយកព្រះរាជហឫទ័យទុកជាក់ប៉ុន្មាន, ដោយហេតុនេះ ព្រះកែវមរកតទើបគប់នៅក្នុងស្រុកយោនកជៀងសែន ។ កាលព្រះព្រហ្មរាជសុគតហើយ ព្រះកែវ-មរកតក៏ត្រូវនិមន្តទៅប្រតិស្ឋាន ទុកនៅជៀងរ៉ាយតមកទៀតអស់វេលាជាយូរឆ្នាំ តែនៅដោយស្ងាត់កំបាំង ។

ព្រះកែវមរកតបានរបូតពីកណ្ដាប់ដៃខ្មែរ ធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃជាតិដទៃ ដោយអាការយ៉ាងនេះ ។

## រយៈទី ៧

# ព្រះកែវមរកតចេញចាកជៀងរ៉ាយ ទៅស្ថិតនៅនគរជៀងម៉ៃ

ប្រមាណក្នុង ព. ស. ២០២០ ដល់ ព. ស. ២០៩២

ក្នុងរវាង ព ស. ១៩៨៥ ដល់២០២៦ ដែលជារជ្ជកាលព្រះបាទតិលោកពជ ព្រះចៅក្រុងជៀងម៉ៃ (ជាតិលាវ) សឹងមានអំណាចគ្របមកដល់ជៀងរ៉ាយ, គ្រានោះមានភិក្ខុចាស់ ១ រូប នៅក្នុងវត្ត ១ ក្នុងស្រុកជៀងរ៉ាយ តែងតែទៅបោសព្រះវិហារជារឿយៗ តែភិក្ខុនោះមិនបានដឹងថាព្រះកែវមរកតនៅក្នុងព្រះវិហារនោះទេ ។ នាថ្ងៃមួយភិក្ខុនោះបានទៅបោសដូចកាលសព្វដង ទទួលប្រទះព្រះពុទ្ធរូប ១ អង្គ របេះបាយអដែលគេស្រោបឃើញជាព្រះកែវ, បានប្រាប់ដំណឹងនេះដល់ចៅអធិការវត្តនិងអ្នកដទៃៗទៀត ។ គេក៏ផ្អើលនាំគ្នាមកមើលឈូឆរ ហើយនាំគ្នាកេះបាយអចេញឃើញជាព្រះពុទ្ធរូបកែវមរកត ។

សេចក្ដីនេះមិនស្ងាត់បាត់ បានជ្រាបដល់ព្រះចៅតិលោកពជៗ ទ្រង់សោមនស្សណាស់ត្រាស់ឲ្យក្នាក់ងារ យកដំរីមកទទួលនិមន្តព្រះកែវមរកតយកទៅឯនគរជៀងម៉ៃ ។ កាលនាំទៅដល់ផ្លូវបែកទៅលំប៉ាង (នគរខេលាង្គចាស់) និងផ្លូវទៅនគរជៀងម៉ៃ ដំរីក៏ផ្អើលរត់ទៅតាមផ្លូវទៅលំប៉ាង,

ទ្រម័កទាញទប់នឹងញាក់ឲ្យទៅផ្លូវជៀងម៉ៃដូចម្ដេចក៏មិនព្រមទៅ គោង បណ្ដោយទៅតាមចិត្តវា ។ កាលទៅដល់លំប៉ាង ភ្នាក់ងារអ្នកនាំក៏ យកព្រះកែវមរកតទៅប្រគល់ឲ្យព្រះសុវណ្ណមាត្យ ជាចៅហ្វាយស្រុក នៅទីនោះឲ្យរក្សាទុកជាបណ្ដោះអាសន្ន ហើយទៅក្រាបទូលព្រះចៅ តិលោកករាជតាមដំណើរ ។

ព្រះចៅតិលោកករាជកាលបើទ្រង់ជ្រាបហើយ ត្រាស់ឲ្យសាងវិហារ នៅវត្តជោតិការាម ( វត្តចេតិយហ្លួង ) នៅក្រុងជៀងម៉ៃជាប្រញាប់ស្រេច ហើយ ត្រាស់ឲ្យលើកក្បួនមកនិមន្តព្រះកែវមរកតពីនគរខេលាង្គ ទៅ ប្រតិស្ឋាននៅព្រះវិហារថ្មី ទ្រង់ធ្វើសក្ការៈបូជាដរាបលុះអស់ព្រះជន្ម ។

ព្រះកែវមរកតចេញពីជៀងរ៉ាយ ទៅប្រតិស្ឋាននៅនគរជៀងម៉ៃ ប្រមាណពី ព. ស. ២០២០ (?) ដល់ ព. ស. ២០៩២ រួមវេលា ប្រមាណ ៧២ ឆ្នាំ, ដោយអាការៈយ៉ាងនេះ ។

## រយៈទី ៨

## ព្រះកែវមរកតចេញចាកនគរជៀងម៉ៃ ទៅស្ថិតនៅក្រុងវៀងចន្ទន៍ប្រទេសលាវ ក្នុងកាល

**ព. ស. ២០៩២ ដល់ ព. ស. ២៣២១**

កាលក្នុង ព. ស ២០៩០ ព្រះជ័យជេដ្ឋាធិរាជឱរសព្រះចៅ ពោធិសាររាជនៅក្រុងវៀងចន្ទន៍ ព្រះជន្មបាន ១៤ ឆ្នាំ បានទៅគ្រង

រាជសម្បត្តិនៅនគរជៀងម៉ៃ ទ្រង់គោរពព្រះកែវមរកតខ្លាំងណាស់ ។ លុះដល់ឆ្នាំ ព.ស. ២០៩២ ព្រះចៅពោធិសាររាជជាព្រះរាជបិតាសោយទិវង្គតនៅក្រុងវៀងចន្ទន៍ ។ ព្រះជ័យជេដ្ឋាក៏ស្តេចទៅថ្វាយព្រះភ្លើងព្រះបរមសពព្រះរាជបិតា បានទាំងនិមន្តយកព្រះកែវមរកតទៅផង ដោយទ្រង់គិតថា ស្តេចយាងទៅនេះ ប្រហែលជាត្រូវទទួលសោយរាជសម្បត្តិនៅក្រុងវៀងចន្ទន៍ផង ទើបទ្រង់និមន្តយកជាប់នឹងព្រះអង្គទៅ ។ កាលស្រេចថ្វាយព្រះភ្លើងព្រះបរមសពហើយ គេក៏អញ្ជើញឲ្យឡើងសោយរាជ្យស្នងព្រះរាជបិតាតមក មិនបានស្តេចត្រឡប់នគរជៀងម៉ៃវិញទេ ។ ទ្រង់បានសាងព្រះវិហារ ១ យ៉ាងធំ សម្រាប់ប្រតិស្ឋានព្រះកែវមរកត ព្រះវិហារនោះ គង់នៅដល់សព្វថ្ងៃនេះ ។

ព្រះកែវមរកតចេញចាកនគរជៀងម៉ៃ ទៅប្រតិស្ឋាននៅនគរវៀងចន្ទន៍ រហូតដល់ឆ្នាំ ព.ស. ២៣២១ ដោយអាការយ៉ាងនេះ ។

### រយៈទី ៩

## ព្រះកែវមរកតចេញចាកនគរវៀងចន្ទន៍ ទៅស្ថិតនៅក្រុងធនបុរីប្រទេសថៃ

### ក្នុងកាល ព.ស. ២៣២១

កាលព្រះចៅតាកស៊ិនសោយរាជ្យបាន ១១ ឆ្នាំ គឺក្នុងឆ្នាំ ព.ស. ២៣២១ បានត្រាស់ប្រើព្រះចៅព្រះយ៉ាចក្រី (ដួង) ជាមហាក្សត្រិយ៍សឹក

ឲ្យលើកទ័ពទៅកម្រាបក្រុងសតនាគនហុត រហូតដល់ក្រុងវៀងចន្ទន៍ ។ កាលព្រះមហាក្សត្រិយ៍សឹកទៅដល់ក្រុងវៀងចន្ទន៍ បានឃើញព្រះកែវមរកតនៅក្នុងព្រះវិហារព្រះកែវ ក៏និមន្តយកមកថ្វាយព្រះចៅតាក់ស៊ិន ។ ទ្រង់ទទួលប្រតិស្ឋានទុកនៅក្រុងធនបុរីអស់វេលា ៧ ឆ្នាំ ។

កាលព្រះចៅតាកស៊ិនទិវង្គតហើយ ព្រះចៅព្រះយ៉ាចក្រី ( ដួង ) បានឡើងសោយរាជ្យតមក ទ្រង់បានច្លងមកសាងព្រះរាជវាំងនៅត្រើយខាងកើត ( គឺនៅបាងកកសព្វថ្ងៃនេះ ) ហើយសាងព្រះវិហារ ១ នៅក្នុងកំពែងព្រះរាជវាំងទិសខាងត្បូង សម្រាប់ប្រតិស្ឋានព្រះកែវមរកតនោះ ហៅថា វត្តព្រះស្រីរតនសាស្តារាម ។ ព្រះកែវមរកតស្ថិតក្នុងក្រុងទេព ( បាងកក ) ដរាបដល់សព្វថ្ងៃនេះ ។

ព្រះកែវមរកតចេញចាកក្រុងវៀងចន្ទន៍មកស្ថិតនៅបាងកក ដោយអាការយ៉ាងនេះ ។

បូករួមអាយុព្រះកែវមរកត តាំងពីសាងមកដល់បច្ចុប្បន្នកាលនេះ ប្រមាណ ២៤៨០ ឆ្នាំថ្វាយ ។

**ប្រវត្តិព្រះកែវមរកតចប់ដោយសង្ខេបតែប៉ុណ្ណេះ**

# រឿងជាងបងជាចោរ

## សាមណេរ គក - គីទៀង វត្តឧណ្ណាលោម ភ្នំពេញ

ប្រែរៀបរៀង ជាកាព្យពាក្យ ៧

ឃុនសុវត្ថិវេទី យូរ-អ៊ុន ពិនិត្យកែ

(ត ចប់)

---

ក្រិណានោះបុរសជាស្វាមី អស្តង្គតរស្មីព្រះសុរិយា
ចេញមកដល់ខ្ទមគេប្រាប់ថា ប្រពន្ធយាត្រាទៅស្រុកហើយ ៗ
ទើបប្តីកិតភ័យប្រឹងរត់តាម ទឹកភ្នែកហូរហាមពុំមានស្បើយ
ទួញថាឱប្អូនសង្សារអើយ ម្តេចឡើយកាត់ចិត្តចាកស្នេហា ៗ
ប្រហែលជាប្អូនមិនអាណិត អាសូរដល់ចិត្តបងទេ៎
កំពុងស្រឡាញ់ពេញចិន្តា ម្តេចប្អូនស្នេហាដាច់អាល័យ ៗ
ទួញហើយរត់តាមទាន់យប់នោះ តែអកុសលគ្រោះកាចចង្រៃ
បណ្តាលភ្លៀងផ្គរព្យុះខ្លាំងក្រៃ ស្រីទន់ជើងដៃភ័យមហិមា ៗ
នាងឈឺពោះដេកលើផែនដី ឯប្តីកិតភ័យស្មុះម្មា
នាងដេកស្រែកទ្រួញក្នុងព្រឹក្បា ឥតមានអ្នកណាបានដឹងឡើយ ៗ
ពេលភ្លៀងនោះនាងប្រសូតកូន ក្នុងព្រៃស្ងាត់សូន្យយំព្រលើយ
លុះនាងប្រសូតកូនរួចហើយ ញាប់ញ័រឥតស្បើយសព្វកាយា ៗ
កូនតូចកូនធំយំក្អែងៗ អាសូរសំឡេងកុមារា

ក្នុងកត្រីស្ងាត់នាព្រៃក្បា ភ្លៀងផ្គរសង្ឃ្រព្រួខ្លួរខ្លារ ៗ
នាងក្រាបក្រុងកូនទាំងពីរពៀរ បែកក្បាលជង្គង់បែងការពារ
ចំណែកស្វាមីភ័យស្លុះស្លារ ទៅពុំយូរយាររកកាប់ឫស ៗ
ដើម្បីដុតអាំងកំដៅប្រាណ បដាចារកល្យាណក្នុងកាលនោះ
ដើរទៅពវស្លួបរកកាប់ឫស មានទពស់វែកមួយពិសយ៉ាងខ្លាំង ៗ
ព្រួសស្ទូរចេញមកចឹកចំពៀម ពីសរតែពេលថ្មើមជាច់ជីវិត
ស្លាប់ស្តុកដេកស្តឹងរូបរឹងគាំង រូបអើយអនិច្ចំក្នុងព្រៃក្បា ៗ
ចំណែកភរិយាចាំយូរពេក ស្ងាត់សូន្យវិវេកក្នុងចិន្តា
ទន្ទឹងស្វាមីខ្លាំងពេកណា ហើយបីបុត្រាដើរទៅតាម ៗ
ដឹកដៃកូនធំបីកូនខ្ចី ជាស្រីស្រែកទួញក្អែករហាម
ប្រញាប់ប្រញាល់ត្រាច់គន់ស្នាម ដើរតាមស្រែកហៅរកសាមិកា ៗ
នាងបានឃើញប្ដីដេកស្តុកស្តឹង ឥតដឹងស្មារតីក្នុងព្រៃក្បា
នាងលូកដៃស្ទាបសព្វកាយា ដឹងថាប្ដីក្ស័យដូច្នោះហើយ ៗ

នាងអួលអាក់អន់ស្បើរធ្លាក់ថ្លើម ដង្ហើមធុញថប់ឥតមានស្បើយ
ទួញថាឱះឱស្វាមីអើយ ស្លាប់ហើយចោលខ្ញុំនៅកំព្រា ៗ
អ្នកធ្លាប់រស់នៅរួមសុខទុក្ខ ពីនេះទៅមុខប្អូនវេទនា
មិនគួរអ្នកមកក្ស័យជន្មា ឲ្យប្អូនកំព្រាដូច្នេះសោះ ៗ
អ្នកស្លាប់ចោលប្អូនគូពិសី ចោលទាំងកូនខ្ចីនៅបៅដោះ

ពេលទាំងកូនបងឲ្យក្រៀមក្រោះ ឲ្យប្អូនរងគ្រោះទុក្ខស្ល័រក្ស័យ ។
បើនៅជាមួយអ្នកជាខ្មោច រែងខ្លោចផ្សាចិត្តពន់ពេកក្រៃ
នឹងទៅពេលអ្នកចិត្តអាល័យ អ្នកនៅក្នុងព្រៃតែម្នាក់ឯង ។
អ្នកមានតែសត្វជាបរិវារ នៅតែឯការែងកណ្ដែង
មានតែហ្វូងសត្វដើរខ្វាត់ខ្វែង បំបែងចិត្តណាស់ណាមាសថ្លៃ ។

ណ្ហើយចុះប្អូនសូមលាអ្នកទៅ សំដៅមាតុភូមិតាមនិស្ស័យ
ធ្វើម្ដេចកម្មយើងកាចចង្រៃ ឲ្យអ្នកប្រុសថ្លៃក្ស័យពេលទៅ ។
នាងលាខ្មោចប្ដីស្រេចកាលណា ទំនួញសោកាសែនក្ដួលក្ដៅ
អាក់អួលក្ដុកក្ដួលចុកណែននៅ ខំកាត់ចិត្តទៅក្នុងព្រឹក្សា ។
ដៃឆ្វេងនាងដឹកដៃកូនច្បង ដៃស្ដាំត្រកងកូនពៅណា
សម្រក់ទឹកភ្នែកទន់កាយា ដើរក្នុងព្រឹក្សាខ្លាចសត្វផង ។

កូនតូចកូនធំស្រែកយំថ្ងូរ គួរឲ្យអាសូរពេកកន្លង
នាងទួញលួងលោមកូនទាំងសង កែវល្អងម្ដាយអើយនាងកុំយំ ។
កូនអើយនុ៎ះហ្ន៎សត្វសារិកា វានាំឈ្មោលញីស៊ីបេកទុំ
ដូចម្ដាយកាលដើមនៅជួបជុំ ឥឡូវឪមុំមណ៍ដីវា ។
កូនអើយអ្នកមើលនុ៎ះសត្វខ្វែង វាហើរខ្វាត់ខ្វែងឃ្លាតពីគ្នា
ដូចម្ដាយបែកពីឪពុកបា កំព្រាខ្លោចផ្សាពុំមានស្បើយ ។
កូនចូរមើលសេកហើរទាំងគូ បីដូចម្ដាយស៊ូចេញមកហើយ

ពាំនាក់បីតាកូនត្រាណាត្រើយ    កូនអើយឥឡូវម្ដាយខ្លោចផ្សា ៗ
កូនបួរមើលស្វាឧបមេវ៉ា    ដូចកូនស្ងួនគ្មានមាតា
ម្ដាយបីថ្នាក់ថ្នមដឹកដៃបា    អនិច្ចាចិត្តណាស់ណាកូនម្ដាយ ៗ
កូនអើយកុំយំមើលព្រឹក្សព្រៃ    ឈើខ្ពស់ទ្រៃឈៃមែកត្រសាយ
មានទោចឈ្មោលញីលោតប្រញាយ    បេះផលទាំងឡាយប្រឡែងគ្នា ៗ
មើលដើមស្រុកដុះប្រកិត    ស្រុកក្រំចិត្តទ្រាំវេទនា
ដើមស្ដៅម្ដាយស្ដាយឥតគណនា    មិនគួរឃ្លាតឃ្លាបិតាអ្នក ៗ

កូនអើយពីថ្ងៃនេះទៅមុខ    ខ្លួនម្ដាយបានទុក្ខព្រួយឥតអាក់
ដូចផែនថ្មធំគេលើកដាក់    ទំលាក់លើទ្រូងធ្ងន់ណាស់ណា ៗ
ទុក្ខម្ដាយក៏ធ្ងន់យ៉ាងនោះដែរ    មិនស្រាកមិនល្ហែពីកាយា
កូនអើយកុំយំកុំសោកា    អាណិតមាតាណាមាសម្ដាយ ៗ

លុះនាងដើរផុតព្រៃនោះទៅ    ឃើញស្ទឹងមួយនៅជិតមិនឆ្ងាយ
នាងគិតភ័យខ្លាំងញ័រអង្គកាយ    ត្រីផងទាំងឡាយហែលត្រៀបត្រា ៗ
នាងដាក់កូនធំត្រើយអាយខ្វី    ហើយបីកូនខ្ចីឆ្លងស្ទឹងថ្លា
ដល់ត្រើយហើយបេះស្លឹកព្រឹក្សា    ក្រាលផ្ដេកបុត្រាហើយត្រឡប់ ៗ
មកយកកូនធំនៅត្រើយអាយ    ភិតភ័យក្នុងកាយញ័ររំប្រប់
ទឹកព្រួយក្នុងចិត្តសែនធុញថប់    ត្រឡប់បែរមុខមើលកូនខ្ចី ៗ
មានសត្វខ្លែងមួយធំចំឡែក    ធំប្លែកជាងសត្វខ្លែងប្រក្រតី

ហើយរើលក្រឡឹងជិតកូនខ្ចី    រំពៃគិតស្មានថាមំសា ។
នាងឃើញទះដៃស្រែកដេញខ្វីង    កូនធំនោះឯងគិតស្មានថា
ម្ដាយបក់ដៃហៅកេអាត្មា    ស្រវាំចុះទឹកលង់ស្លាប់ទៅ ។
បំណែកកូនខ្ចីខ្វីងឆាបយក    ទៅលើពពកខ្ពស់សន្ធៅ
នាងស្ទុះធ្លោះភ្លាក់ទឹកជ្រៅ    ស្លាប់កូនគ្មាននៅសល់មួយឡើយ ។
មុខគួរអាសូរនាងណាស់សា    ស្រែកទួញយំថាមាសម្ដាយអើយ
ម្ដាយបានទរណាពីងជាត្រើយ    កូនអើយអ្នកស្លាប់ចោលមាតា ។
ម្ដាយខំដឹកដៃពថ្នាក់ថ្នម    ម្ដាយខំបីបមថែរក្សា
ឥឡូវកម្មកូនសូន្យដាច់    ព្រាត់ចោលមាតាស្លាប់បាត់ឈឹង ។
ពីថ្ងៃនេះទៅខ្លួនមាតា    ពុំក្សាន្តចិន្តាទុក្ខតានតឹង
ស្លាប់កូនស្លាប់ប្ដីកម្មអ្វីហ្នឹង    បើមុនទ្រង់ម្ដាយទ្រាំម្ដេចបាន ។
រួចទើបនាងធ្ងន់ផុតស្ទឹងនោះ    ដើរត្រោះទៅជួបប្រុសឯកា
នាងសួរថាអ្នកមកពីណា ?    គេថាខ្ញុំមកពីសាវត្ថី ។
នាងសួរថាអ្នកស្គាល់បិតា    ញាតិកានៃខ្ញុំដែរឬអី ?
គាត់ជាអ្នកមានធនធានល្បី    ធ្វើជាសេដ្ឋីក្រុងនេះណា ។
ប្រុសនោះប្រាប់ថានែអ្នកស្រី    សេដ្ឋីបិតានឹងមាតា
នៃអ្នកភ្លើងឆេះស្លាប់អាត្មា    យប់មិញនេះណាគ្មានសល់ឡើយ ។
ខ្យល់ព្យុះបក់ផ្ទះភ្លើងឆេះអស់    គ្មានសល់របស់អ្វីសោះហើយ
ខ្ញុំកំពុងស្ដាយពុំទាន់ស្បើយ    មើលចុះនុ៎ះហើយឃើញតែផ្សែង ។

នាងស្តាប់ស័ព្ទច្បាស់ទះដើមទ្រូង    ស្រែកទ្ញួញរលួងត្អែង ៗ
ឱកម្មអ្វីឲ្យផលជាក់ស្តែង    អញពេញចំបែងទ្រូងខ្លោចផ្សា ៗ
ស្លាប់ឪពុកម្តាយកូនសូន្យឈឹង    មិនដឹងជាពឹងអ្នកឯណា
មានតែខ្លួនមួយព្រួយចិន្តា    ឱនេះចំជាទុក្ខស្មើរប្រេះ ៗ
នាងព្រួយព្រើនត្រួតឆ្កួតវង្វេង    កម្មព្រេងមកផ្តល់ក្នុងពេលនេះ
ភ្លេចសំពត់អាវរបូតរបេះ    គ្មានបេះការពារកេរ្តិ៍និន្ទា ៗ
អ្នកផងឃើញអាក្រាតដូច្នោះ    អៀនខ្មាសក្នុងពោះមហិមា
ទើបដេញចោលនាងតែពល់គ្នា    គួរឲ្យវេទនាអនេកលន់ ៗ
ដូនជាគ្រានោះព្រះសាស្តា    កំពុងទេស្នាប្រោសពួកជន
ដោយហេតុកុសលពីជាតិមុន    បន្ទន់ចិត្តនាងឲ្យដើរចំ ៗ
ដល់ហើយឈរក្រោយក្រុមបរិស័ទ្យ    ដែលកាត់មកស្តាប់ធម៌ឧត្តម
បរិស័ទ្យឃើញដូច្នោះដេញបន្ទំ    កុំឲ្យឈរយំជិតសាស្តា ៗ
ព្រះអង្គកាលទតឃើញហេតុនោះ    ទ្រង់មានអនុគ្រោះត្រាស់តបថា
កុំឃាត់នាងបដាចារ    បើកឲ្យយាត្រាចូលមកអាយ ៗ
មហាជនលែងដេញលែងឃាត់ខាំង    នាងដើរចូលទាំងអាក្រាតកាយ
អង្គុយចំភ័ក្ត្រស្រស់ពណ្ណរាយ    ស្តាប់ធម៌ស្ងប់កាយស្ងប់ចិន្តា ៗ
លុះស្តាប់ធម៌ព្រះប្រែស្មារតី    ជាស្រីលែងឆ្កួតលែងលលា
ពួកជនឲ្យសំពត់ពានា    រុំព័ទ្ធកាយារពេចខ្លី ៗ
លុះនាងស្លៀកហើយទូលព្រះអង្គ    សូមទ្រង់ប្រោសប្រាណត្រាប្រណី

ដ្បិតខ្ញុំកំសត់លើសអស់ស្រី
មានប្ដីៗស្លាប់ក្នុងព្រៃក្បា ។
កូនប្រុសធំលូនលង់ទឹកស្លាប់
កូនខ្ញុំខ្លែងចាប់ជាកក្បា
បំណែកមាតានឹងបិតា
ក្រណាំក្បាយដ៏អស់សូន្យឈឹង ។
ខ្លួនខ្ញុំនេះគ្មានអ្នកឯណា
ពំនាក់អាត្មាគ្រាន់ទីពឹង
ឲ្យបាត់ទុក្ខព្រួយក្នុងគ្រាហ្នឹង
សូមពឹងព្រះអង្គស្មើជីវិត ។
ព្រះពុទ្ធទ្រង់មានពុទ្ធដីកា
នែបដាចារនាងកុំគិត
ទីពឹងទាំងនោះឃើញខុសពិត
ចូរគិតលះបង់ដោយប្រាជ្ញា ។
របស់ទាំងនោះតែងវិនាស
និកស្រពាត់ប្រាសជាធម្មតា
បំណែកមនុស្សសត្វសង្ខារ
គ្មានអ្នកឯណាបានសុខឡើយ ។
នេះព្រោះតែសាងកម្មអកុសល
ឲ្យបានទុក្ខទល់មិនមានស្បើយ
ដូច្នេះចូរនាងកុំកន្ដើយ
ចូរធ្វើឲ្យស្បើយចាកទុក្ខា ។
ចូរនាងទីពឹងដល់ព្រះពុទ្ធ
ព្រះធម៌បរិសុទ្ធសឹងថ្លៃថ្លា
ទីពឹងព្រះសង្ឃទ្រង់សីលា
នឹងរួចទុក្ខាពុំខានឡើយ ។
ព្រះអង្គសំដែងច្រើនប្រការ
លុះចប់ទេសនាពេលណាហើយ
នាងលុះសោតាបុនសុខស្បើយ
រួចហើយសុំបួសពេលនោះណា ។
បដាចាភិក្ខុនី
ជាស្រីមិនយូរកាលវេលា
សម្រេចអរហត្តក្នុងចិត្ត
ដោយសារទីពឹងព្រះពុទ្ធថ្លៃ ។
រឿងនាងបដាចារនេះឯង
ខ្ញុំតែងសង្ខេបបំប្រួញន័យ
ច្នេះសូមអស់លោកឲ្យអភ័យ
ទោសពៃរ៍កុំបីនិន្ទាអើយ ។ (ចប់)

# ប្រវត្តិព្រាហ្មណ៍ចាស់

# លោក អ៊ុម-គយ សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់

(ត ចប់)

---

បានជាឈ្មោះថា "បុព្វាចារ្យ" ព្រោះលោកជាគ្រូអាចារ្យបង្ហាត់បង្រៀន មានបង្រៀនឲ្យចេះនិយាយស្ដីនិងគួរសម ស៊ីចុក ដេកដើរជាដើម មុនជាងគ្រូអាចារ្យឯទៀតៗ ។ បានជាឈ្មោះថា "អាហុនេយ្យបុគ្គល" ព្រោះមាតាបិតា គួរដើម្បីទទួលគ្រឿងបូជា ដែលកូនប្រុសស្រីលើកមកជូន គឺថាបុត្រធីតាណាបានបូជាលោកហើយ រមែងបានផលានិសង្សច្រើន ដូចជាបានបូជាចំពោះព្រះអរិយបុគ្គល ។

បំណែកខាងការធ្វើអាក្រក់ គឺសំឡាប់មាតាបិតា លោកចាត់ចូលក្នុងអនន្តរិយកម្ម ។ នោះមាន ៥ យ៉ាងគឺ មាតុឃាត (សំឡាប់មាតា) ១ បិតុឃាត (សំឡាប់បិតា) ១ អរហន្តឃាត (សំឡាប់ព្រះអរហន្ត) ១ លោហិតុប្បាទ (ធ្វើព្រះលោហិតនៃព្រះសម្មាសម្ពុទ្ធឲ្យបែកចេញ) ១ សង្ឃភេទ (បំបែកសង្ឃ) ១ ។ ការសំឡាប់មាតាបិតានេះ ជាអំពើមានទោសធ្ងន់បំផុតប៉ុនទឹងទោសសំឡាប់ព្រះអរហន្តដែរ ព្រោះមាតាបិតាជាព្រះអរហន្តរបស់កូនប្រុសស្រី ។ ការធ្វើល្អ ឬអាក្រក់ចំពោះមាតាបិតា ក៏បានផលច្រើន ដូចជាធ្វើល្អឬអាក្រក់ ចំពោះព្រះអរហន្តទីណាស្រេចដែរ ។ ព្រោះហេតុនោះ សាធុជនគួរតែគោរពកោតអានបូជា

ចំពោះព្រះអរហន្តដែលនៅជាមួយនឹងយើងរាល់ថ្ងៃ ពិតមែនតែយើងកើតមកមិនទាន់ព្រះអរហន្តជាទីណា ស្រេចលោកបរិនិព្វានហួសទៅហើយ យើងមិនបានថ្វាយបង្គំបូជាដោយបច្ច័យ, ប៉ុន្តែបើមាតាបិតាយើងនៅរស់ យើងមិនមែនឈ្មោះថា ឥតកំព្រាសំណាងទេ ឈ្មោះថាមានលាភហើយ ព្រោះលោកជាព្រះមួយរបស់បុត្តធីតារាល់រូប ៗ ដូច្នេះ យើងគួរកុំព្រងើយកន្តើយ កុំធ្វើឲ្យលោកអន់អាក់ត្រែណាក់ចិត្ត គប្បីថ្វាយបង្គំបូជាដោយគ្រឿងសក្ការៈផ្សេង ៗ សមដូចពុទ្ធភាសិតថា:

តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យ ច បណ្ឌិតោ
អន្នេន អថោ បានេន វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន បាទានំ ធោវនេន ច ។

"ព្រោះហេតុនោះ កូនប្រុសស្រីជាបណ្ឌិត គប្បីថ្វាយបង្គំនូវមាតានឹងបិតានោះផង គប្បីរាប់អាននូវមាតានឹងបិតានោះដោយចំណី ទឹក សំពត់ ទីដេក គ្រឿងក្រអូប គ្រឿងគក់ ទឹកលាងជើងផង" ។

អ្នកដែលទំនុកបំរុងចិញ្ចឹមមាតាបិតា រមែងមិនថ្លស់ធ្លោយធ្លាក់ខ្លួនទៅក្នុងទីទាបថោកឡើយ រមែងបានចំរើនដោយបុណ្យយសសក្តិធំខ្ពង់ខ្ពស់ ដោយលំដាប់ដូចព្រះចន្ទខាងខ្នើត នឹងបានទទួលពាក្យសរសើរអំពីសំណាក់អ្នកប្រាជ្ញ លុះដល់រំលាងបញ្ចក្ខន្ធទៅ រមែងបានទៅកើតក្នុងស្ថានសួគ៌សមដូចពុទ្ធភាសិតថា:

យោ មាតរំ បិតរំ វា  មច្ចោ ធម្មេន បោសតិ
តាយ នំ បារិចរិយាយ  មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ  បេច្ច សគ្គេ បមោទតិ ។

"អ្នកឯណា ចិញ្ចឹមមាតា ឬបិតា ដោយធម៌, ព្រោះការបំរើប្រតិបត្តិចំពោះមាតាបិតានោះ ពួកបណ្ឌិតតែងសរសើរអ្នកនោះក្នុងលោកនេះ លុះអ្នកនោះក្ស័យជីវិតទៅ រមែងរីករាយក្នុងស្ថានសួគ៌ទៀត" ។

អ្នកដែលចិញ្ចឹមបំរុងមាតាបិតានោះ មិនមែនគ្រាន់តែបានទទួលពាក្យសរសើរអំពីអ្នកប្រាជ្ញក្នុងលោកនេះទេ សូម្បីពួកទេវតាក៏តែងសរសើរបុគ្គលនោះដែរ សមដូចព្រះពុទ្ធភាសិតថា :

មាតាបេត្តិភរំ ជន្តុំ  កុលេ ជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ  បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ  សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតឹសា  អាហុ សប្បុរិសោ ឥតិ ។

"ពួកទេវតា ក្នុងជាន់ត្រៃត្រិង្ស តែងហៅនរជនប្រុសស្រីដែលចិញ្ចឹមមាតាបិតា, ប្រព្រឹត្តកោតក្រែងបុគ្គលជាធំក្នុងត្រកូល, មានសំដីពីរោះ, ពោលពាក្យនាំឲ្យកើតមិត្រ, លះបង់ពាក្យញុះញង់, ប្រាសចាកសេចក្ដីកំណាញ់, មានពាក្យសត្យ, គ្របសង្កត់សេចក្ដីក្រេវក្រោធ នោះថាជាសប្បុរស" ។

មិនមែនគ្រាន់តែបានទទួលគោរម្យងារថា "សប្បុរស" ប៉ុណ្ណោះទេឡើយ សូម្បីខ្លួនមានគ្រោះថ្នាក់ដល់ស្លាប់ ក៏គង់រួចចាកសេចក្ដីស្លាប់នោះបាន តួយ៉ាងដូចព្រះពោធិសត្វកាលកើតជានន្ទិយម្រឹគ ៗ

សេចក្ដីដំណាលថា: ព្រះមហាក្សត្រមួយអង្គសោយរាជ្យក្នុងក្រុងសាកេត នាកោសលរដ្ឋ មិនប្រកបដោយទសពិធរាជធម៌ តែងនាំបណ្ដារាស្ត្របរបាញ់សត្វទាំងរដូវប្រាំងវស្សា ៗ ពួករាស្ត្រមិនអាចធ្វើការរបររកស៊ីបានឡើយ ទើបនាំគ្នាធ្វើឃ្នងក្នុងឧទ្យាន ហើយកៀងម្រឹគបញ្ចូលក្នុងឃ្នងនោះ ដើម្បីឲ្យស្ដេចងាយបាញ់ផង ខ្លួនក៏បានឱកាសធ្វើការងារផង ៗ គ្រានោះ ព្រះពោធិសត្វកើតជានន្ទិយម្រឹគ បាននាំពង្រត់មាតាបិតាភៀសចេញពីព្រៃធំទៅពួនសម្ងំក្នុងគុម្ពោតឈើតូច, កាលគេលើកព្រៃដល់ទីនោះ, បានលះបង់ជីវិតជូនមាតាបិតា ហើយរត់ទៅម្នាក់ឯងចូលទៅក្នុងឃ្នងនោះ ៗ

តស្មឹ ខណេ ក្សណនោះព្រះរាជាតែងបាញ់ម្រឹគក្នុងឃ្នងនោះតាមវេន ក្នុងមួយថ្ងៃមួយៗ ៗ ថ្ងៃមួយត្រូវវេនម្រឹគពោធិសត្វក៏ចេញមកឈរទៀបមាត់ទ្វារ ហើយផ្សាយមេត្តាចិត្តចំពោះស្ដេច ៗ ដោយគុណដែលបានទំនុកបំរុងលះជីវិតជូនមាតាបិតានិងមេត្តាធម៌នោះ ព្រះរាជាមិនអាចបាញ់បាន ទើបទ្រង់លាន់ព្រះឱស្ឋថា "ឱ! ស្នាធ្នូដែលធ្វើពីកំណាត់ឈើ ជារបស់ឥតចិត្តវិញ្ញាណទេ ម្ដេចក៏វាដឹងថាម្រឹគនេះមានគុណធម៌ល្អ

កូនខ្លួន អាត្មាអញជាមនុស្សត្រឡាំង ម្តេចក៏មិនដឹងគុណធម៌របស់ម្រឹគនេះសោះ" ទ្រង់បានឲ្យអភ័យដល់នន្ទិយម្រឹគព្រមទាំងពួកម្រឹគដ៏សេស ៗ រីឯនន្ទិយម្រឹគទូន្មានព្រះរាជាថា "បពិត្រមហារាជ! តាំងពីថ្ងៃនេះទៅ សូមទ្រង់លះបង់អគតិទាំង ៤ ចេញ ហើយសោយរាជ្យប្រកបដោយទសពិធរាជធម៌ ១០ ប្រការ" រួចពោលពាក្យជាគាថាថា:

ទានំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ
អក្កោធំ អវិហឹសញ្ច ខន្តិញ្ច អវិរោធនំ
ឥច្ចេតេ កុសលេ ធម្មេ ឋិតេ បស្សាមិ អត្តនិ
តតោ តេ ជាយតេ បីតិ សោមនស្សញ្ចនប្បកំ ។

"(បពិត្រមហារាជ) សូមព្រះអង្គទ្រង់ពិចារណានូវកុសលធម៌ គឺទសពិធរាជធម៌ ១០ ប្រការនេះគឺ ការឲ្យទាន ១, ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ មួយដងមួយកាល ១, ការបំណាយព្រះរាជទ្រព្យទំនុកបំរុងព្រះនគរ ១, មានសេចក្តីត្រង់ ១, មានសេចក្តីទន់ភ្លន់សុភាពរាបសា ១, ការកាន់ឧបោសថសីលតាមកាលកំណត់ ១, មិនកំដៅពេលអាលអ្នកដទៃ ១, មិនបៀតបៀនអ្នកដទៃ ១, មានសេចក្តីអត់ធ្មត់ ១, មិនបំពានលើច្បាប់លើធម៌ ១ ដោយព្រះអង្គឯង, ព្រោះការ

ប្រព្រឹត្តនូវទសពិធធម៌ទាំង ១០ នោះ បីតិនឹងសោមនស្ស រមែងកើតដល់ព្រះអង្គជានិច្ច ។

ធម៌ទាំង ១០ នេះសំរាប់ព្រះរាជាប្រព្រឹត្តផ្ទាល់ព្រះអង្គ ព្រមទាំងណែនាំសេនាបតីនាម៉ឺនមុខមន្ត្រីតូចធំ ទាំងពួករាស្ត្រឲ្យប្រព្រឹត្តតាមផង ៗ

ឯវមាយំ ធម្មទេសនា សង្ខេបេន សមត្តា ធម៌ទេសនានេះសូមសន្មតថាចប់ដោយសង្ខេប សមគួរដល់កាលវេលា ឯរំ ដោយនូវប្រការអំបាលនេះហោង ៗ

សុភាសិត

អ្នកមានចំណេះវិជ្ជាល្អ ប៉ុន្តែមិនប្រព្រឹត្ត
ឲ្យសមគួរនឹងវិជ្ជានោះ នឹងឈ្មោះថាជា
មនុស្សល្អព្រមមិនបាន ។

យូរ-អ៊ុន

# ពិធីផ្ទេរពុទ្ធសាសនបណ្ឌិត្យ
# ជូនមករាជរដ្ឋាភិបាលខ្មែរ

នៅថ្ងៃ ១៨ ខែតុលាឆ្នាំ ១៩៥០ ក្នុងវេលាព្រឹកម៉ោង ៩ នឹង ១៥ នាទី មានធ្វើពិធីផ្ទេរពុទ្ធសាសនបណ្ឌិត្យជាផ្លូវការ ជូនមករាជរដ្ឋាភិបាលខ្មែរ ។ ពិធីនេះធ្វើនៅក្រោមព្រះរាជាធិបតី នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ដើម្បីឲ្យឃើញនូវអត្ថរសនៃអធិបតេយ្យខាងក្នុងប្រទេស ដែលជាផលនៃសន្ធិសញ្ញា ចុះថ្ងៃ ៨ ខែវិច្ឆិកា ១៩៤៩ ។

ក្នុងថ្ងៃដែលធ្វើពិធីនេះ មន្ទីរពុទ្ធសាសនបណ្ឌិត្យ មានការតាក់តែងដោយគ្រឿងលំអផ្សេងៗ : ខ្លោងទ្វារខាងកើតរចនាដោយកម្រងផ្កានឹងស្លឹករុក្ខជាតិ ដ៏ប្រដាប់ដោយទង់ជាតិខ្មែរ - បារាំង ។ នៅទីជួលប្របខ្លោងទ្វារនេះ មានកងទាហានក្រុមរក្សាព្រះអង្គ នឹងក្រុមក្មេងព្រះរាជទ្រព្យ ឈរនៅចាំធ្វើការគោរព ។ ខាងក្នុងនៃមន្ទីរក៏ប្រដាប់ដោយកម្រងផ្កាស្លឹករុក្ខជាតិនឹងទង់ជាតិ គួរឲ្យទស្សនាដូចខាងក្រៅដែរ តែត្រង់ល្វែងធំដ៏ទូលំទូលាយនោះ រៀបចំជាទីសម្រាប់សន្និបាត សឹងពាសពេញទៅដោយតុនឹងកៅអី ដែលមានក្រាលព្រំយ៉ាងល្អជាទ្រនាប់ ។

ការរៀបចំតាក់តែងមន្ទីរដោយគ្រឿងលំអក្នុងពិធីនេះ ជាស្នាដៃនៃព្រះតេជព្រះគុណ មាស - ហែល រដ្ឋមន្ត្រីក្រសួងធម្មការនឹងសិល្បការ រាប់ថាជាភស្តុតាងស ឲ្យឃើញថា លោកពេញចិត្តជាទីបំផុតនឹងរាជការបារាំង ដែលផ្ទេរក្រសួងនេះមកឲ្យរាជរដ្ឋាភិបាលខ្មែរវិញ ។

លុះដល់ពេលដែលកំណត់ថា ត្រូវជួបជុំហើយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, លោកកុម្មិសែរដឹឡាវេពុយត្រឹក ប្រចាំកម្ពុជរដ្ឋ, ព្រះអង្គក្រុមហ្លួនមុនីពង្ស នាយករដ្ឋមន្ត្រី, សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា, ព្រះគ្រូអរិយកស្សប អ៊ូច ជាតំណាងសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ, សមាជិករដ្ឋាភិបាល, ព្រះសង្ឃជាច្រើនអង្គ ព្រមទាំងឥស្សរជនខ្មែរ - បារាំងជាច្រើននាក់ទៀត បានស្តេចយាង និមន្ត - អញ្ជើញទៅប្រថាប់ - គង់ - អង្គុយលើអាសនៈ (កៅអី) ដែលរៀបចំទុក ក្នុងកិច្ចដ៏ថ្លៃថ្លានេះ ។

ក្នុងពេលដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងមកដល់ហើយ, នោះលោកុបិស់សឺលិយេ ជាអគ្គិរក្សនៃសារមន្ទីរអាល់ប៊ែរសារ៉ូ បានថ្លែងនូវសុន្ទរកថាមួយក្នុងនាមនៃរដ្ឋាភិបាលបារាំង រៀបរាប់អំពីប្រវត្តិនៃពុទ្ធសាសនបណ្ឌិត្យ ដែលតាំងពីកើតមក តែងបានសេចក្តីចំរើនពុំដែលដាច់ ហើយមានពន្លឺនាមខ្ចរខ្ចាយខ្ពួទៅដល់ប្រទេសជិតខាង ។

បន្ទាប់មក ព្រះតេជព្រះគុណ មាស - ហែល ជារដ្ឋមន្ត្រីក្រសួងធម្មការនឹងសិល្បការ បានសូត្រនូវសុន្ទរកថាមួយ ថ្លែងសេចក្តីត្រេកអរចំពោះរដ្ឋាភិបាលបារាំង ដែលបានផ្តួរផ្តើមស្ថាននេះ ។

លុះចប់សុន្ទរកថានេះហើយ ព្រះសង្ឃទាំងឡាយសូត្រជ័យមង្គលជូនពរស័ព្ទសាធុការឲ្យអង្គការនេះបានចំរើនតរៀងទៅ ។

ក្នុងទីបំផុត លោកស៊ុទ្ធវេស ជានាយកប៉ូយរ៉ូបានចុះហត្ថលេខា តំណាងលោកកុម្ម៉ៃស៊ែរដឺឡាវេពុយពឹក ជាមួយនឹងព្រះតេជព្រះគុណ មាស-ហែល លើសេចក្ដីកត់ហេតុសម្រេចអំពីការផ្ទេរនេះ ។

## សុន្ទរកថានៃលោកបិស៉ស៊ីលីយេរ

អភិវឌ្ឍន៍សារចន្ទ័រ អាល់បែរសាំរ៉ូ កាន់តំណែងបណ្ដោះអាសន្នជាអគ្គលេខាធិការនៃក្រុមពុទ្ធសាសនបណ្ឌិត្យ ។

ព្រះករុណា ជាម្ចាស់ជីវិតលើត្បូង,

លោកស្នងការនៃសាធារណរដ្ឋ,

សម្ដេច,

ទ្រង់,

ព្រះថេរានុត្ថេរៈ,

ព្រះតេជព្រះគុណ,

អ្នកស្រី លោកអ្នកទាំងឡាយ,

ក្នុងព្រឹត្តិការណ៍ដ៏ឧឡារិកដែលមានមកក្នុងកាលឥឡូវនេះ ហើយចំពោះកិត្តិយស ដែលខ្ញុំត្រូវទទួលក្នុងការស្ដែងសុន្ទរកថា ក្នុងនាមនៃរដ្ឋាភិបាលបារាំង ខ្ញុំមិនអាចធ្វើឲ្យចិត្តដែលរំជួលខ្លាំងរបស់ខ្ញុំឲ្យស្ងប់ទៅបាន . . . ;

ខ្ញុំនខ្ញុំអ្នកបុរាណវត្ថុ, តែដោយថៃជន្យក្នុងទេសកាល, ទៅជាបានមកគប់ប្រសព្វនឹងក្រុមបណ្ឌិត្យដែលបានសិក្សាខាងភាសាសំស្ក្រឹត នឹងបាលី

ថែមទាំងទទួលរៀបចំខាងការផ្ទេរក្រុមពុទ្ធសាសនបណ្ឌិត្យ ទៅរដ្ឋកិច្ចាល កម្ពុជរដ្ឋ; ពុទ្ធសាសនបណ្ឌិត្យនេះខ្ញុំក៏ព្រមនឹងទទួលចុះហត្ថលេខាខ្ទះនៅលើលិខិតក្នុងកិច្ចការផ្សេង ៗ បានជាសេចក្តីរីករាយចិត្តខ្លាំងរបស់ខ្ញុំនេះ គួរទុកជាធម្មានុរូបបាន ហើយខ្ញុំសូមទទួលសារភាពដោយសេចក្តីអៀនខ្មាស ថាកិច្ចដែលផ្ទេរនេះប្រកបដោយសង្ក្រាត គឺភាវៈច្របូកច្របល់បន្តិច ៗ ហេតុម្តេចបានជាកិច្ចការទាំងនេះទើបនឹងទទួលអនុវត្តន៍ក្នុងពេលថ្ងៃនេះ, ក្នុងកាលបរិច្ឆេទដូចជាយឺតយូរបន្តិច ? ដោយមានទោសកាលដែលប្រាសចាកពីឆន្ទៈរបស់យើង ព្រមទាំងការរៀបចំសម្ភារៈក្នុងកិច្ចផ្ទេរអង្គការមួយ ដូចពុទ្ធសាសនបណ្ឌិត្យ ដែលមានសារៈប្រយោជន៍ ហើយត្រូវប្រើរយៈវេលាអស់យូរកាលជាសម្បើមអស្ចារ្យ នេះឯងជាហេតុនាំឲ្យបន្ថយថ្ងៃផ្ទេរនោះរហូតមកដល់ពេលនេះ ។

តាមសេចក្តីពិត ទោះបីលិខិតជាផ្លូវការដែលសម្រេចនូវរបៀបប្រតិបត្តិការទើបនឹងចុះហត្ថលេខានៅថ្ងៃនេះ តែចំណែកខាងប្រទេសបារាំងបានព្រមព្រៀងភ្លាម នូវបែបបទជាវិធីប្រតិបត្តិតាំងពីមុនថ្ងៃចុះហត្ថលេខា ក្នុងកិច្ចព្រមព្រៀងនោះ, ទាំងមុនសេចក្តីសម្រេចក្នុងសន្ទនាការនូវកិច្ចព្រមព្រៀងនេះទៀត ។ តាំងពីលោកម៉ារទីន អគ្គលេខាធិការនៃក្រុមពុទ្ធសាសនបណ្ឌិត្យ ចាកចេញពីប្រទេសកម្ពុជានៅថ្ងៃ ២៧ ខែមករាមុននេះ, លោកស្រី ប៉ូរ-ម៉ាស្ស៊ឿរ, រហូតមក ខ្លួនខ្ញុំគ្រាន់តែជាអ្នកទទួលភារៈខាងចាត់កិច្ចការសាមញ្ញប៉ុណ្ណោះ ។

វិជានការនេះ គឺមានជាប់តមក ក្រោយដែលបានប្រគល់សាលាបាលីជាន់ខ្ពស់ ពីថ្ងៃ ៣១ ខែធ្នូ ១៩៤៨, បញ្ជាក់ឲ្យឃើញនូវសេចក្ដីខ្វះខ្វែងរបស់រដ្ឋាភិបាលបារាំង ដែលមានបំណងចង់ផ្ដើរវិជ្ជាស្ថានទាំងពីរ ដែលជាមូលដ្ឋានពិតប្រាកដនៃវប្បធម៌ខ្មែរ ។

គេទុកជាយល់ខុស, បើមានគេយល់ថាកម្មិកភាពដែលនាំពុទ្ធសាសនបណ្ឌិត្យទៅកាន់វឌ្ឍនធម៌ជាថ្មីនេះ គ្រាន់តែជាប្រតិបត្តិការត្រឹមរដ្ឋបាលមានការគមនាគមន៍ខាងគ្រឿងសម្ភារៈ គឺបណ្ណាល័យមួយ មានសៀវភៅច្រើនល្មម សារមន្ទីរមួយជាបន្ទួរ, មានបុគ្គលិក, មន្ទីរព្រមទាំងគ្រឿងសង្ហារិមនឹងទីទុកឯកសារប៉ុណ្ណោះ ។ ទុកជាមិនបានយល់ជាក់ច្បាស់នូវកិច្ចការខាងផ្លូវប្រាជ្ញដ៏សុខុមដែលអង្គការនេះ បានបំពេញហើយនឹងសារៈប្រយោជន៍សំខាន់នៃចំណោះផ្សេងៗ ដែលបានអប់រំក្នុងវិជ្ជាស្ថាននេះ ។ ក្រុមជំនុំព្រះត្រៃបិដកនឹងក្រុមជំនុំទំនៀមទម្លាប់ បានដំណើរកិច្ចការទាំងនេះ ផ្សាយទៅមិនសូវបានជ្រួតជ្រាបដល់ប្រជាជនគ្រប់ៗគ្នាទេ, តែបើតាមគោលការណ៍នៃវិជ្ជាស្ថានទាំងពីរ មានរបៀបពិតប្រាកដដូចវិជ្ជាស្ថានខាងមជ្ឈិមប្រទេស ។ សេចក្ដីពន្យល់ខាងលើនេះ នៅមិនទាន់គ្រប់គ្រាន់បរិបូណ៌ល្មមបំភ្លឺនូវអត្ថន័យឲ្យបានពេញលក្ខណៈចំពោះពុទ្ធសាសនបណ្ឌិត្យ ដែលជាទីប្រជុំនៃច្បាប់ប្រពៃណីខាងផ្លូវប្រាជ្ញនឹងប្រជាជាតិ ដែលគេទុកជាបដិមាតំណាងនាមនឹងរូបនៃ

ជាតិខ្មែរទាំងមូល ជាមូលដ្ឋាននៃសេចក្ដីស្មានរុងរឿងដែលកើតមកពី អចលនសទ្ធា, ពីចិន្ដាជាបឋម, ព្រមទាំងវប្បធម៌ដែលស្ថិតនៅ ដោយសេចក្ដីស្មោះស្ម័គ្រតាមលទ្ធិបូរាណពីអតីតកាល ។

ពុទ្ធសាសនបណ្ឌិត្យបានស្ថាបនាឡើងពីឆ្នាំ ១៩៣០ ដោយបាន ប្រែកែបណ្ណាល័យ ដែលមានព្រះរាជប្រកាស ១៩២១ ចាត់តាំងពីមុន មក ។ ពុទ្ធសាសនបណ្ឌិត្យនេះបានដំណើរការតមក ចំរើនវឌ្ឍនា-ការតាមលំដាប់ គ្មានឧបសគ្គអ្វីមកពាំងពាឡើយ ។ វិជ្ជាស្ថាននេះតែង រក្សានូវកិត្យានុភាព ដែលជាប់ទាក់ទងទៅនឹងលទ្ធិដែលល្បីល្បាញក្នុង សកលលោក ព្រមទាំងអភិបាលទុកនូវកេរ្ដិ៍តំណែលនៃស៊ីវិល្យ៍ពីសម័យ បុរាណ តែមិនអាចជួបប្រទះនឹងគ្រោះថ្នាក់ ឬវិបត្តិផ្សេងៗ ដូចជា វិជ្ជាស្ថានឯទៀតដែលមានបំណងហួសមាឌ ឬមានសភាពប្លែកពីធម្មជាតិ តែងធ្លាប់កប់ប្រសព្វនោះឡើយ ។

ពុទ្ធសាសនបណ្ឌិត្យនេះកើតឡើងដោយ "ព្រះរាជបំណងនៃព្រះករុណា ជាម្ចាស់ជីវិតលើត្បូងនៃកម្ពុជរដ្ឋនឹងហ្លួងច្បាប់" ដើម្បីនឹងបំពេញកិច្ចទៅ តាមសេចក្ដីត្រូវការដ៏ជ្រាលជ្រៅនៃពួកពុទ្ធបរិស័ទ ។ វិជ្ជាស្ថាននេះ ស្ថាប-នាឡើងដើម្បីជាជំនួយដល់សាលាបាលីជាន់ខ្ពស់នឹងព្រះរាជបណ្ណាល័យ ។ វិជ្ជាស្ថាននេះមាននាមថា "វិជ្ជាស្ថានសម្រាប់ការសិក្សាខាងពុទ្ធសាស-នាហីនយាន" បានផ្សាយរាតកម្មិកភាពរហូតដល់ប្រទេសលាវកម្ពុជា

ព្រមទាំងក្រុមជនជាតិខ្មែរខាងប្រទេសកូស័ងស៊ីន ៗ ដល់មក គ.ស. ១៩៣៣ ពុទ្ធសាសនបណ្ឌិត្យនេះត្រឡប់ទៅជាមាននាមថា "វិជ្ជាស្ថានសម្រាប់ការសិក្សាខាងពុទ្ធសាសនា" ហើយមានបេសកកម្មត្រង់ការណែនាំព្រមទាំងប្រមូលនូវវត្ថុធាតុផ្សេងៗ ចំពោះការសិក្សាខាងព្រះពុទ្ធ-សាសនាហីនយាន ។ ដល់មក ខែកុម្ភៈ ១៩៤៣ វិជ្ជាស្ថាននេះប្រែនាមថា "ពុទ្ធសាសនបណ្ឌិត្យឥណ្ឌូចិន" ហើយបានទទួលពីព្រះរាជបណ្ណាល័យនូវអំណោយផ្សេងៗមានសៀវភៅជាច្រើនផ្នែកខាងវិទ្យាសាស្ត្រ ៗ តាំងពីនោះមក, វិជ្ជាស្ថាននេះបានរក្សាទុកនូវសៀវភៅផ្នែកខាងភាសាសាស្ត្រ (Philologie) សាសនា, ប្រវត្តិសាស្ត្រ, បុរាណវត្ថុវិទ្យាខាងបូព៌ាប្រទេស ហើយក៏បានចាត់ចែងបោះពុម្ពសៀវភៅ ក្នុងនាមនៃព្រះរាជបណ្ណាល័យនឹងសាលាបាលីជាន់ខ្ពស់ទុកដូចជារបស់ខ្លួន ៗ គ្រោងការណ៍ដែលធ្វើនេះ នាំឲ្យវិជ្ជាស្ថានដែលមានសភាពទន់ខ្សោយនៅឡើយសម្រេចបានតាមបំណង ៗ ឥឡូវនេះ, វិជ្ជាស្ថាននេះគេទុកជាអង្គការសេរីការបស់រដ្ឋសេរីការហើយ ជាស្ថានទីកម្មិកភាពនៃវប្បធម៌មានប្រយោជន៍ដ៏សំខាន់បំផុត ៗ ពិតមែនតែមានវិបត្តិសម្ភារៈនឹងសីលធម៌ដែលសកលលោកទើបនឹងបានឆ្លងរួចមកហើយ, ដែលមានកំសួលកាលជាលមកដល់វិជ្ជាស្ថាននេះ តែការបម្រើនវ័យវឌ្ឍនាការក៏បានធ្វើដំណើរទៅតាមលំដាប់ឥតឈប់ឈរសោះឡើយ ៗ ការបោះពុម្ពព្រះត្រៃបិដកជាស្នាដៃឯក

សម្បើមអស្ចារ្យ ដែលវិជ្ជាស្ថានទេះបានចាត់ឲ្យផ្ទៀងផ្ទាត់តាមច្បាប់ដើម ព្រមទាំងឲ្យបកប្រែនូវវិន័យព្រះពុទ្ធសាសនា ជាភាសាបាលីមានចំនួនសៀវភៅទាំងអស់ ១១០ ដែលអាក់ខានបោះពុម្ពហើយ, ឥឡូវទើបនឹងរៀបោះពុម្ពជាថ្មី នូវភាគ ៣៦ និង ៣៧ ក្នុងរយៈវេលាពីរបីខែមុននេះ ។

រថយន្តបណ្ណាល័យដែលមាននាមថា រថយន្តកំសាន្ត ឬ វិស្សមៈ (Auto des loisirs) បាននាំប្រតិសព្ទកម្មិកភាពនៃពុទ្ធសាសនបណ្ឌិត្យ ដោយស្មោះស្ម័គ្រទៅផ្សាយទួទៅតាមភូមិ, ឥឡូវទ្រុឌទ្រោមគ្រាំគ្រារលាយបាត់ទៅហើយ ។ ដោយហេតុមានទេសកាលដ៏លំបាកខ្លាំង រថយន្តនេះមិនអាចរករថយន្តឯទៀតមកជំនួសបាន ហើយគួរឲ្យស្រយុតចិត្តពន់ពេកបើកាលណាគេយល់អំពីសារៈប្រយោជន៍សំខាន់ ដែលរថយន្តនេះបានធ្វើ ។ ត្រូវយើងទៅសួរនាតាមវត្តអារាម ដែលស្ថិតនៅឆ្ងាយពីទីក្រុងដូចជាខ្ញុំបានធ្លាប់គប់ប្រសព្វម្តងមួយកាល, ដើម្បីនឹងប្រែបយកនូវអារម្មណ៍ដែលនាំឲ្យកើតសេចក្តីសង្ឃឹម ព្រមទាំងការគមនាគមន៍ពិតប្រាកដខាងចិន្តាចំពោះរថយន្តនេះក្នុងកាលជាអនាគត ។

ខ្ញុំបានបង្ហាញនូវសេចក្តីលំបាកដែលក្រុមជំនុំព្រះត្រៃបិដកបានជួបប្រទះពីមុនមកក្នុងការបោះពុម្ពព្រះត្រៃបិដកនេះ តែសេចក្តីលំបាកទាំងនេះ មិនអាចជាឧបសគ្គរាំងរាំងនូវសេចក្តីព្យាយាមសមាជិកនៃក្រុមជំនុំនេះដែលបានអប់រំទៅតាមវិន័យដ៏វិសេសវិសាលពន់ពេក ។

ចំណែកខាងក្រុមជំនុំទំនៀមទម្លាប់បានស្ថាបនាឡើងក្នុងរយៈវេលាពីរ - បីឆ្នាំមុននេះ មកពីមានដើមគំនិតនិយមទៅតាមបុរាណគតិក្រុមជំនុំនេះ, ដោយមានលោកស្រី ប៉ូរេ - ម៉ាស្ប៉េរ៉ូ ជាអ្នកញាំងកម្មិកភាព បានសម្រេចនូវស្ថាប័នមួយនេះ ដែលគេកំណត់ទុកជាវិជ្ជាស្ថាននៃប្រជាជាតិពិពណ៌នា (ethnographie) ហើយបានរៀបចំនឹងប្រមូលនូវឯកសារផ្សេងៗ ទៅតាមវិធីទំនើប ៗ ពីឆ្នាំមុន លោកស្រីបានប្រមូលឯកសារ ៣.៦០០ ច្បាប់ហើយបានយកទៅថតជាបន្ទាស់ក្រដាសកុនតូច ៗ (microfilmés) ហើយក្នុងឆ្នាំនេះបានថតឯកសារចំនួន ៤.០០០ ច្បាប់ថែមទៀត ។ ចំណែកខាងបណ្ណាល័យ, មានសៀវភៅប្រមាណ ១០.០០០ ក្បាល, ខ្លះបោះពុម្ព, ខ្លះសរសេរដៃ, ច្រើនជាសៀវភៅមានតម្លៃ ។

គីតយន្តដ្ឋាន (Discothèque) មានប្រមាណ ៣០០ថាសទុកជាមធ្យោបាយដ៏ប្រសើរខាងការឃោសនា ។ តែគួរឲ្យអាណោចអាធ័មពន់ពេក, ដូចជាក្រុមជំនុំព្រះត្រៃបិដក, ក្រុមជំនុំទំនៀមទម្លាប់និងគីតយន្តដ្ឋាន ក៏បានទទួលនូវផលដ៏លំបាកនៃមហាសង្គ្រាមសកលលោកដែរ : លំបាកខាងផ្លូវគមនាគមន៍ដែលរាំងរកមិនឲ្យរៀបចំនូវបណ្ណាល័យនោះឲ្យបានចំរើន, ដោយហេតុគ្មានបឋមវត្ថុធាតុ (matières premières)

(មាន៩)